No.

ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)
ក្រសួងធនធានទឹក និង ឧតុនិយម
ព្រះរាជាណាចក្រកម្ពុជា

# ការសិក្សាស្តីអំពី
# ការស្តារ និង ស្ថាបនាឡើងវិញនូវប្រព័ន្ធផលិតកម្មកសិកម្ម
# ក្នុង
# តំបន់អាងទឹកស្លាគូ ព្រះរាជាណាចក្រកម្ពុជា

# សង្ខេប
# របាយការណ៍បញ្ចប់

មីនា ឆ្នាំ ២០០២

នីប៉ុងកូអេ ខូ លីមីធីត
ធូកុង ខូ លីមីធីត
ប៉ាសកូ អិនធ័រណាស្យូណាល់អ៊ីន

| | |
|---|---|
| A F A | |
| J R | |
| 02 ― 15 | |

# សង្ខេប

# ជំពូកទី I ពត៌មានទូទៅ និង ប្រវត្តិ

## I-1 សេចក្តីផ្តើម :

1. សេចក្តីសង្ខេបនៃរបាយការណ៍បញ្ចប់ បានរៀបចំឡើងដោយក្រុមសិក្សារបស់ JICA យោងទៅលើគំរោងការងារ (Scope of work) សំរាប់ការសិក្សាទៅលើការស្តារ ជួសជុល និង កសាងឡើងវិញនូវប្រព័ន្ធផលិតផលកសិកម្មនៅក្នុងតំបន់អាងទឹកស្ទឹងស្លាគូ ក្រោមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និង ក្រសួងធនធានទឹក និងឧតុនិយម (ក្រ.ធ.ទ.ឧ) ។ រាជរដ្ឋាភិបាលកម្ពុជា និងទីភ្នាក់ងារជប៉ុនសំរាប់សហប្រតិបត្តិការអន្តរជាតិ (JICA) នៅថ្ងៃ 09 ខែ តុលា ឆ្នាំ 2000 ដែលរបាយការណ៍បានបង្ហាញ : i) ពត៌មានទូទៅ និង ប្រវត្តិ ii) ការសិក្សាប្លង់មេសំរាប់តំបន់សិក្សា iii) ការសិក្សាជំរើសទៅលើតំបន់ស្រោចស្រពនៃគំរោងសាងសង់ឡើងវិញនៃប្រព័ន្ធស្រោចស្រពផ្នែកខាងលើស្ទឹងស្លាគូ (USP) iv) ការសិក្សាដំបូងទៅលើអាទិភាពរបស់គំរោងដែលបានជ្រើសរើសតាមរយៈផែនការមេ ។

2. តំបន់សិក្សាប្រមាណសរុប 650 គ.ម$^2$ ដែលស្ថិតនៅប្រហែល 70 គ.ម ផ្នែកនិរតីនៃទីក្រុងភ្នំពេញ និងលាតសន្ធឹងភាគច្រើននៅផ្នែកខាងស្តាំនៃស្ទឹងស្លាគូ ។ តំបន់សិក្សា គឺមានតំបន់រដ្ឋបាលគ្របដណ្តប់ភាគច្រើននៅក្នុងខេត្តតាកែវ និងមួយផ្នែកក្នុងខេត្តកំពង់ស្ពឺ ដែលស្ថិតតាមបណ្តោយព្រំប្រទល់នៃស្ទឹងស្លាគូផ្នែកខាងជើង ហើយដែលខេត្តកំពត ស្ថិតនៅផ្នែកខាងត្បូង និងខាងលិច ព្រមទាំងផ្លូវជាតិលេខ 2 និងផ្លូវដែកស្ថិតនៅខាងកើតតំបន់សិក្សា (មើលផែនទីភូមិសាស្ត្រ) ។

3. គោលបំណងទាំងឡាយនៃការសិក្សាគឺ : i) ដើម្បីរៀបចំនូវផែនការមេមួយសំរាប់ការសាងសង់ឡើងវិញនូវប្រព័ន្ធកសិកម្ម និងការអភិវឌ្ឍន៍នៃផ្នែកខាងលើ និងកណ្តាលនៃតំបន់អាងទឹកស្ទឹងស្លាគូឱ្យដូចជាប្រព័ន្ធគំរូមួយសំរាប់ការកសាងឡើងវិញ និងការអភិវឌ្ឍន៍នៃប្រព័ន្ធស្រោចស្រពទាំងអស់ដែលមានជំរៅមិនសូវជ្រៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា ii) ដើម្បីគ្រប់គ្រងទៅលើតំបន់សិក្សាដំបូងនៃអាទិភាពទាំងអស់របស់គំរោង ។ iii) ដើម្បីផ្ទេរនូវបច្ចេកទេសទៅឱ្យបុគ្គលិក ដែលជាសមភាគីតាមរយៈការបណ្តុះបណ្តាលក្នុងការងារនៃវគ្គសិក្សា ។

## I-2 ប្រវត្តិនៃការសិក្សា

4. ផលចំណូលសរុបតាមគ្រួសារ (GDP) នៃប្រទេសកម្ពុជា គឺមានកំរិតទាបបំផុតដែលប្រមាណ 265 ដុល្លាអាមេរិក ក្នុងឆ្នាំ 1999 ។ កសិកម្ម គឺជាប្រភពសំខាន់នៃសេដ្ឋកិច្ចកម្ពុជាដែលផ្តល់ប្រមាណ 43% នៃ GDP និង 80 % នៃកំលាំងពលកម្ម ។ អាហារចំបងសំរាប់ជនកម្ពុជា គឺស្រូវដែលជាដំណាំកសិកម្មចំបង ។ សរុបផ្ទៃដីនៃប្រទេសកម្ពុជាមាន 181 035 គ.ម$^2$ ក៏ប៉ុន្តែផ្ទៃដីស្រែចំការប្រមាណ 2 លាន ហ.ត និងផ្ទៃដីដាំដុះពីរលើកគឺមានតែ 16 % ប៉ុណ្ណោះ ។ ទិន្នផលស្រូវជាមធ្យមទៅលើកំរិតជាតិ គឺទាបប្រមាណ 1,69 ត/ហ.ត ។

5. ចំនួនប្រជាពលរដ្ឋកម្ពុជាមាន 11.437.656 ក្នុងឆ្នាំ 1998 ។ សមាជិកគ្រួសារជាមធ្យម 5,2 នាក់ ។

84% នៃពលរដ្ឋរស់នៅជនបទ និង 42% នៃប្រជាជនជនបទនេះស្ថិតនៅក្រោមបន្ទាត់នៃភាពក្រីក្រ ។ បញ្ហានៃភាពក្រីក្រជារឿយៗផ្អែកទៅលើមូលដ្ឋាននៃសង្គម និងបញ្ហាសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា ។

6. ស្ថិតនៅក្រោមលក្ខណៈទាំងនេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតឡើងនូវផែនការអភិវឌ្ឍន៍ប្រាំឆ្នាំលើកទី 2 (2001-2005) និងដែលទទួលជោគជ័យផែនការលើកទី 1 (1996-2000) ។ គោលដៅចំបងទាំងអស់នៃផែនការ គឺការអភិវឌ្ឍន៍នៃសេដ្ឋកិច្ចជាតិ និងការកាត់បន្ថយភាពក្រីក្រ ។ ដើម្បីនឹងធ្វើឱ្យបានសំរេចពេញលេញនៃគោលដៅទាំងនេះ វាជាប្រការសំខាន់ណាស់ដើម្បីឈានទៅបង្កើនប្រាក់ចំណូល និងស្ថានភាពរស់នៅរបស់ប្រជាជនជនបទ ។ សំរាប់បញ្ហានេះ កសិកម្ម និងការអភិវឌ្ឍន៍ការស្រោចស្រព ត្រូវបានសង្ឃឹមទុក ។

# ជំពូកទី II ការសិក្សាផែនការមេសំរាប់តំបន់សិក្សា

## II-1 តំបន់សិក្សា

7. រដ្ឋបាលមូលដ្ឋាន និងសហគមន៍ជនបទនៅក្នុងប្រទេសកម្ពុជា គឺមានរចនាសម្ព័ន្ធខេត្ត ស្រុក ឃុំ និងក្រុម ។ ឃុំ គឺស្ថិតនៅកំរិតទាបនៃរដ្ឋបាលសាធារណៈ ។ ចំនួនភូមិនៅក្នុងតំបន់សិក្សាមានប្រមាណសរុប 276 ដែលចំនួន 23 ស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ និង 253 នៅខេត្តតាកែវ ។

8. ចំនួនពលរដ្ឋសរុប និងគ្រួសារនៅក្នុងតំបន់សិក្សាប្រមាណជា 165.600 និង 33.000 គ្រួសារ ។ ចំនួនសមាជិកក្នុងគ្រួសារជាមធ្យម គឺ 5,0 នាក់/គ្រួសារ ។ តំបន់សិក្សានេះមានចំនួនសរុប 650 គ.ម$^2$ និងដង់ស៊ីតេពលរដ្ឋបានប៉ាន់ប្រមាណ 255 នាក់/គ.ម$^2$ ។

9. កំរិតកំពស់នៅក្នុងតំបន់សិក្សាលាតសន្ធឹងពីកំរិតកំពស់ 6 ម៉ែត្រ ទៅដល់កំរិតកំពស់ 60 ម៉ែត្រ ។ លក្ខណៈរបស់ស្រទាប់ដីនៅក្នុង និងជុំវិញតំបន់សិក្សាមានល្បប់ខ្សាច់ ល្បាយខ្សាច់ និងល្បាយភក់ ។

10. ប្រព័ន្ធនៃលក្ខណៈខ្យល់រដូវត្រូវបានគ្របដណ្តប់ទៅលើអាកាសធាតុនៃប្រទេសកម្ពុជា ។ រដូវវស្សាចាប់ផ្តើមពីខែ ឧសភា រហូតដល់ខែ វិច្ឆិកា ហើយដែលរដូវប្រាំងចាប់ផ្តើមពីខែ ធ្នូ រហូតដល់ខែ មេសា ។ ខែមេសា និងខែ ឧសភា ជាខែដែលក្តៅបំផុត និងមានអនុភាពរំហួតខ្ពស់ ។ កំពស់ទឹកភ្លៀងប្រចាំឆ្នាំប្រមាណ 1.200 មម. នៅក្នុងតំបន់ទំនាប និងប្រមាណ 90 % នៃទឹកភ្លៀង គឺនៅរដូវភ្លៀង ហើយដែលខ្ពស់បំផុតនៅខែតុលា ។ ភ្លៀងធ្លាក់ គឺមានការប្រែប្រួល និងជារឿយៗមានកំរិតជំនន់ធំ ។

11. នៅក្នុងតំបន់នោះគ្មានទិន្នន័យទឹកភ្លៀងនៃប្រព័ន្ធស្ទឹងស្លាគូទេ ។ គឺមានតែស្ទឹងព្រែកត្នោតដែលជាអាងជិតខាងនៃអាងទឹកស្ទឹងស្លាគូ (បង្ហាញក្នុង **Figure II-1.3.1**) ដែលជាការកត់ត្រាធារទឹកសំរាប់រយៈពេល 3 ទៅ 4 ឆ្នាំ ។ គំរូកំពស់ទឹកភ្លៀងធ្លាក់ គឺភាគច្រើនដូចគ្នាសំរាប់អាងទឹកទាំងពីរ និងលក្ខខ័ណ្ឌនៃការវាស់កំរិតកំពស់ដី និងគំរូការប្រើប្រាស់គឺដូចគ្នា ។ ដូច្នេះរំហូរនៃស្ទឹងស្លាគូបានប៉ាន់ស្មានជាមូលដ្ឋានប្រចាំខែសំរាប់រយៈពេល 20 ឆ្នាំ ។ ដែលជាបន្តបន្ទាប់ 1966-1969 និង 1985-2000 និងដែលតាមការវិភាគទំនាក់ទំនង

រាំងរំហួរនៃស្ទឹងព្រែកត្នោត និង ទឹកភ្លៀង (បង្ហាញក្នុង **Figure II-1.3.2**) ។ ការប៉ាន់ស្មានរំហូរបីប្រភព នៃផ្នែកតំបន់អាងទឹក បង្ហាញក្នុងផែនទីភូមិសាស្ត្រនឹងសរុបដូចនេះ :

**ធារទឹកប៉ាន់ប្រមាណប្រចាំខែនៅអាងបីក្នុងរយៈពេល 5 ឆ្នាំ និង 2 ឆ្នាំ**

ឯកតា : ម$^3$/វិនាទី

| ឈ្មោះអាង | រយៈពេលកំណត់ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មធ្យមភាគ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ខ្ទបត្របែក | 5 ឆ្នាំ | 0.08 | 0.04 | 0.02 | 0.01 | 0.01 | 0.01 | 0.32 | 0.47 | 2.25 | 1.84 | 1.19 | 0.30 | 0.55 |
| | 2 ឆ្នាំ | 0.13 | 0.06 | 0.03 | 0.01 | 0.01 | 0.47 | 0.56 | 1.15 | 3.24 | 4.60 | 1.88 | 0.53 | 1.06 |
| O អូសារាយ | 5 ឆ្នាំ | 0.01 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.08 | 0.12 | 0.75 | 0.62 | 0.39 | 0.09 | 0.17 |
| | 2 ឆ្នាំ | 0.02 | 0.00 | 0.00 | 0.00 | 0.00 | 0.13 | 0.17 | 0.35 | 1.13 | 1.62 | 0.66 | 0.17 | 0.36 |
| ទំនប់លោក | 5 ឆ្នាំ | 0.16 | 0.10 | 0.06 | 0.01 | 0.01 | 0.01 | 0.75 | 1.21 | 5.52 | 4.51 | 2.87 | 0.68 | 1.33 |
| | 2 ឆ្នាំ | 0.28 | 0.19 | 0.09 | 0.02 | 0.01 | 1.16 | 1.42 | 2.83 | 7.87 | 11.17 | 4.55 | 1.28 | 2.57 |

12. ធនធានទឹកទាំងអស់នៃស្ទឹងស្លាគូបានប្រើប្រាស់សំរាប់ការធ្វើស្រែនៅក្នុងតំបន់សិក្សា តាមរយៈការសាងសង់នូវប្រព័ន្ធស្រោចស្រពអាងទឹកក្នុងឆ្នាំ 1970 ។ នាបច្ចុប្បន្ននេះ ប្រភពធនធានទឹកទាំងនេះពុំបានប្រើប្រាស់ឡើយនៅក្នុងតំបន់សិក្សា ។

13. ដីនៅក្នុងតំបន់សិក្សាបានចាត់ជាប្រាំក្រុម : (A) ដីល្បប់ថ្មី (B) ដីល្បប់ (C) ដីគដ្ឋ (D) ល្បាយគដ្ឋតិច (E) ដីក្រហមខ្ចី ។ (មើល **Figure II-1.4.1**) ។ ក្នុងចំណោមក្រុមដីទាំងអស់នេះ ដីល្បាយគដ្ឋតិចគ្របដណ្តប់ភាគច្រើនប្រមាណ 54.000 ហ.ត ឬក៏ 80% នៃតំបន់សិក្សា ។ ដីល្បាយគដ្ឋតិចគឺភាគច្រើនបានធ្វើការដាំស្រូវ ។ ដីទាំងអស់នេះមានភាពសមរម្យសំរាប់ស្រូវ និងដំណាំរួមផ្សំទាំងអស់រួមបញ្ចូល និងបន្លែនៅរដូវវស្សា និងរដូវប្រាំង ក្រោមការស្រោចស្រព ប៉ុន្តែការដាក់ជីមានកំរិតទាប ។

14. ក្នុងចំនួនដី 56.000 ហ.ត នេះ គឺដីដាំដុះសុទ្ធ បានប៉ាន់ប្រមាណប្រហែល 44.240 ហ.ត ឬក៏ 68% នៃផ្ទៃដីសិក្សា និង មានប្រមាណ 24.540 ហ.ត គឺវាលស្រែ និង 1.700 ហ.ត គឺជាដីដំណាំរួមផ្សំ (មើល **Figure II-1.5.1**) ។ ផ្ទៃដីស្រែគ្របដណ្តប់ភាគច្រើនប្រមាណ 96% នៃដីដាំដុះ ឬក៏ 65% នៃដីតំបន់សិក្សា ។ ដីទាំងអស់នេះប្រើប្រាស់សំរាប់ផលិតចំណីអាហារ និងប្រភពចំណូលសំរាប់ប្រជាជនជនបទ ។ ការដាំដុះទាំងអស់ គឺធ្វើឡើងក្នុងរយៈពេលរដូវវស្សា ហើយស្រូវ បន្លែ និងដំណាំផ្សេងៗទៀត ដាំតិចតួចនៅក្នុងរដូវប្រាំង ។

15. យោងទៅលើច្បាប់ប្រើប្រាស់ដីធ្លីដែលប្រកាសឱ្យប្រើក្នុងឆ្នាំ 1992 ដីជាគោលគឺជាកម្មសិទ្ធរបស់រាជរដ្ឋាភិបាលកម្ពុជា និងកសិករទាំងអស់មានសិទ្ធិក្នុងការប្រើប្រាស់ ។ យុទ្ធនាការនៃការចុះបញ្ជីដែលបានអនុវត្តនីក្រោមការិយាល័យចុះបញ្ជីដី ដែលបានចុះបញ្ជីតិចជាង 10% នៃដីស្រែក្នុងប្រទេស ។ ការចែកដីស្រែនៅក្នុងតំបន់សិក្សាមិនបានច្រើនទេ ។ ទំហំដីស្រែក្នុងគ្រួសារនីមួយៗនៅក្នុងតំបន់សិក្សាមានពី 0,09 ទៅ 4,15 ហ.ត និងទំហំស្រែជាមធ្យម 0,80 ហ.ត ។

16. គ្រួសារកសិករទាំងអស់នៅក្នុងតំបន់សិក្សាប្រមាណ 97% នៃចំនួនគ្រួសារសរុប ឬក៏មានប្រមាណ 32.000 គ្រួសារ ។ កំលាំងពលកម្មនៅក្នុងតំបន់សិក្សា គឺបានប៉ាន់ស្មានប្រហែល 74.000 នាក់ ។ ជាមធ្យមកំលាំងពលកម្មក្នុងមួយគ្រួសារប៉ាន់ស្មានប្រមាណ 2,3 នាក់ ។ ប្រព័ន្ធកំលាំងពលកម្មប្រវាស់ដៃ គឺជាទំលាប់ប្រក្រតី សំរាប់ការងារស្រែចំការក្នុងរយៈពេលនៃការដកស្ទូង និងការច្រូតកាត់ ។

17. ស្រូវជាដំណាំចំបងសំរាប់ចំណីអាហារព្រមទាំងជាប្រភពនៃប្រាក់ចំណូលនៃកសិករផងដែរ សំរាប់ជីវិតប្រចាំថ្ងៃនៅក្នុងតំបន់ ។ ការធ្វើស្រែនៅក្នុងតំបន់សិក្សាបានត្រូវចាត់ជាបួនប្រភេទគឺ ស្រូវដើមឆ្នាំ ស្រូវកណ្ដាល ស្រូវចុងឆ្នាំ និងស្រូវប្រាំង ទៅតាមរយៈកាលនៃការលូតលាស់ និង រដូវ ។ ដំណាំរួមផ្សំទាំងឡាយសំរាប់បរិភោគខ្លួនឯង ឬក៏ដំណាំរកកំរៃ គឺជាប្រភពនៃប្រាក់ចំណូលដែលបានដាំដុះនៅក្នុងផ្ទៃដីតូច មុន ឬក៏ ក្រោយការដាំដុះស្រូវក្នុងរដូវវស្សា (មើល **Figure II-1.5.2**) ។

18. ទិន្នផលឯកតានៃស្រូវក្នុងប្រទេសកម្ពុជាបានបំពេញនូវកំណើនឡើងភ្លាមៗ តែទោះបីជាយ៉ាងនេះក្ដី វានៅតែមានកំរិតទាបនៅឡើយគឺ 1,69 ត/ហ.ត ។ ទិន្នផលស្រូវជាមធ្យមនៅក្នុងរដូវវស្សា និង រដូវប្រាំងមានពី 1,53 ត/ហ.ត និង 2,93 ត/ហ.ត ។ ទិន្នផលស្រូវជាមធ្យមនៅក្នុងខេត្តតាកែវមាន 1,8 ត/ហ.ត ក្នុងរដូវវស្សា និង 2,8 ត/ហ.ត នៅក្នុងរដូវប្រាំង និង 2,2 ត/ហ.ត ជាមធ្យមប្រចាំឆ្នាំ ។ ឯកត្តាទិន្នផលនៅក្នុងតំបន់សិក្សាគឺត្រឹមតែ 1,3 ត/ហ.ត ។

19. ការងារស្រែចំការ គឺប្រព្រឹត្តទៅភាគច្រើនដោយកំលាំងពលកម្ម និងកំលាំងសត្វពាហនៈ ដោយគ្មានម៉ាស៊ីនកសិកម្ម ។ ប្រមាណ 70% នៃកសិករបានចិញ្ចឹមសត្វពាហនៈជាកំលាំងភ្ជួររាស់ និង អូសរទេះ ។ កសិករដែលគ្មានសត្វពាហនៈជាកំលាំងអូសទាញ ព្យាយាមភ្ជួររាស់ដីដោយកិច្ចព្រមព្រៀងជាមូលដ្ឋាន ។ ប្រមាណ 30% នៃកសិករពុំបានប្រើប្រាស់ជីគីមីដោយការខ្វះខាតថវិកា ។ ការបោចស្មៅជាទូទៅធ្វើឡើងដោយកំលាំងមនុស្ស ។ ការបាញ់ថ្នាំគីមីសំរាប់រោគឆ្លង និងត្រួតពិនិត្យសត្វល្អិតបំផ្លាញ គឺធ្វើដ៏តិចតួច ។

20. ការចិញ្ចឹមសត្វ គឺជាសកម្មភាពដ៏សំខាន់មួយសំរាប់គ្រប់កសិករនៅក្នុងតំបន់សិក្សា ដែលជាប្រភពប្រាក់ចំណូល និងកំលាំងអូសទាញសំរាប់ការភ្ជួររាស់ដី ។ គ្រួសារកសិករនីមួយៗមានជាមធ្យម 2,6 ក្បាល គោ ក្របី និងជ្រូក 1,7 ក្បាល ព្រមទាំងមាន់ទា 18 ក្បាល ។ ប្រាក់ចំណូលប្រចាំឆ្នាំពីការធ្វើស្រែចំការប្រមាណ 118 ដុល្លាអាមេរិកគឺទាបបំផុត ។ ប្រភពប្រាក់ចំណូលចំបង គឺការចិញ្ចឹមសត្វ (ប្រមាណ 66% នៃប្រាក់ចំណូលសរុប) និងក្រៅពីស្រែចំការ (ប្រមាណ 28% នៃប្រាក់ចំណូលសរុប) ។

21. រាជរដ្ឋាភិបាលកម្ពុជាបានផ្ដល់នូវអាទិភាពខ្ពស់ទៅលើសន្តិសុខស្បៀង គឺស្រូវជាបញ្ហាសំខាន់ ។ ភាពគ្រប់គ្រាន់សំរាប់ខ្លួនឯងនៃស្រូវស្ថិតនៅក្នុងកំរិតជាតិ ដែលធ្វើបានសំរេចតាមរយៈការបង្កើនផលិតផលស្រូវ អាស្រ័យដោយគុណភាពដែលមិនមែនគ្រាន់តែជាការបំពេញចិត្តឡើយ ។ ត្រឹមតែ 2% នៃការផលិតផលស្រូវនៅក្នុងតំបន់សិក្សាលើសពីតំរូវការបន្ទាប់ពីសំរាប់បរិភោគនៅក្នុងតំបន់ ។ ចាប់តាំងតែពីកសិករប្រើប្រាស់អង្ករ ឬ ចុងអង្ករសំរាប់ការចិញ្ចឹមជ្រូក គឺអាចនិយាយថាស្រូវក្នុងតំបន់សិក្សាជាញឹកញាប់មានការខ្វះខាតប្រចាំឆ្នាំ អាស្រ័យដោយផលិតផលទាប និងកសិករទាំងអស់ដែលមានដីស្រែតិចជាងមធ្យម ជារឿយៗតែងតែខ្វះខាតស្រូវ ។

22. ប្រព័ន្ធស្រោចស្រពនៅក្នុងតំបន់សិក្សាមានអាងសំខាន់ៗបី និងប្រលាយមេពីរ ដែលបង្ហាញក្នុងផែនទីភូមិសាស្ត្រ ។ ប្រព័ន្ធនេះបានសាងសង់ឡើងក្នុងរបបប៉ុលពតពាក់កណ្ដាលចុងឆ្នាំ 1970 ។ បន្ទាប់ពី ពីរ បីឆ្នាំក្រោយមក សំណង់ភាគច្រើនរបស់អាងបានត្រូវបំផ្លិចបំផ្លាញដោយសារទឹកជំនន់ អាស្រ័យដោយកិច្ច

ប្រតិបត្តិការពុំបានគ្រប់គ្រាន់ ។ ប្រលាយស្រោចស្រពទាំងអស់បានត្រូវបំផ្លាញ អាស្រ័យដោយសកម្មភាពថែទាំពុំបានសមរម្យ ។

23. អាងទំនប់លោកនៅលើដងស្ទឹងស្លាគូស្ថិតនៅជាគោលសំខាន់ផ្នែកខាងលើនៃផ្ទៃដីស្រោចស្រព ដែលជាសំណង់យកទឹកមួយសំរាប់ប្រព័ន្ធ ។ ទឹកបានបញ្ចេញពីអាងទំនប់លោកនឹងបញ្ជូនទៅអាងអូរសារ៉ាយតាមរយៈប្រលាយភ្ជាប់ ឬ ប្រលាយបញ្ចេញ ដែលបន្ទាប់មកហូរទៅអាងខ្ពបត្របែក ដែលចេញពីប្រលាយមេដំបូង ។ ភាពសំខាន់ផ្សេងៗគ្នានៃអាងទាំងបីបានសរុបដូចខាងក្រោម :

**លក្ខណៈសំខាន់ផ្សេងៗនៃអាងទាំងបី**

| ពិពណ៌នា | ខ្ពបត្របែក | អូរសារ៉ាយ | ទំនប់លោក |
|---|---|---|---|
| 1.ទន្លេ | ដូនភេ | អូរ ក្រូច | ត្រាស់ (ស្លាគូ) |
| 2.ផ្ទៃរងទឹកភ្លៀង | 137 គម$^2$ | 51គម$^2$ | 332 គម$^2$ |
| 3.ជំរេលទន្លេ : ជាមធ្យម | 1/110 | 1/120 | 1/190 |
| 4.ជំរេលទន្លេ : ក្នុងអាង | 1/540 | 1/250 | 1/460 |
| 5.មាឌអាង (ការប៉ាន់ស្មាន) | 2.63 MCM | 0.23 MCM | 1.00 MCM |

24. ប្រលាយមេលេខ 1 ឬ ប្រលាយ 33 សន្ធឹងពីជ្រុងខាងត្បូងនៃផ្លូវស្រុកលេខ 33 បន្តទៅដល់ផ្លូវជាតិលេខ 3 ។ ទឹកដែលចេញពីប្រលាយ 33 គឺបញ្ជូនទៅប្រលាយរងទាំងអស់ដែលភាគច្រើនស្ថិតនៅផ្នែកខាងជើងនៃផ្លូវ 33 តាមរយៈបំពង់បង្ហូរ ឬក៏ ទ្វារទឹកបង្ហូរទាំងឡាយ ។ ប្រលាយលេខ 2 ឬ ប្រលាយកោះក្អែកចាប់ផ្តើមពីអាងខ្ពបត្របែក និងបន្តទៅទិសខាងត្បូងទៅដល់ស្រុកអង្គរជ័យ ខេត្តកំពត ។ ប្រលាយរងទាំងអស់នាំទឹកស្រោចស្រពពីប្រលាយកោះក្អែក និងបញ្ជូនទៅដល់ផ្នែកនិរតីនៃតំបន់សិក្សា ។ ក្នុងរយៈពេលដែលពត៌មានមិនត្រឹមត្រូវកើតមានឡើងលើលក្ខណៈគ្រោងការនៃប្រព័ន្ធស្រោចស្រពដូចជា គំនូរបច្ចេកទេស និង ឯកសារគ្រោងការ ចំនួនផ្ទៃដីស្រោចស្រពសុទ្ធសរុប 30.400 ហ.ត ដែលបានជឿជាក់ សំរាប់រយៈពេលវែង (មើល **Figure II-1.6.1**) ។

25. ក្នុងពេលបច្ចុប្បន្ន ស.ក.ប.ទ ស្របច្បាប់ពុំទាន់មានឡើយនៅក្នុងតំបន់សិក្សា ។ នៅទីនោះមាន ស.ក.ប.ទ បី បួន ដែលស្ថិតនៅជិតខាងតំបន់សិក្សា ។ ស.ក.ប.ទ ទាំងនេះបានបង្កើតឡើងក្នុងរយៈពេលចាប់តាំងពីឆ្នាំ 1994 ដល់ឆ្នាំ 1999 និងដែលគាំទ្រដ៏សំខាន់ដោយអង្គការអន្តរជាតិ ។ ភាគច្រើននៃ ស.ក.ប.ទ ទទួលបន្ទុកការងារដូចជា : i) ប្រតិបត្តិការ និងការថែទាំសំណង់ស្រោចស្រព ii) ប្រមូលសេវាថ្លៃប្រើប្រាស់ទឹក (ISF) ដែលសំរេចដោយគណៈកម្មាការ iii) ដោះស្រាយវិវាទ iv) ការងារគណនេយ្យរបស់ ស.ក.ប.ទ បើទោះណាជាពួកគេមានការលំបាក ឬ បញ្ហាជាច្រើនក្តី ។ យោងទៅលើពត៌មានពី ស.ក.ប.ទ ទាំងឡាយថ្លៃសេវាប្រើប្រាស់ទឹកជាសាច់ប្រាក់ ឬ ក៏ជាអ្វីផ្សេងទៀត ពុំបានប្រមូលពេញលេញ និងអត្រាប្រមូលប្រមាណ 68 % ប៉ុណ្ណោះ ។

26. ក្រោមមាត្រាទី 20 ក្នុងពង្រាងច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៃរាជរដ្ឋាភិបាលកម្ពុជា គ្រប់កសិករទាំងអស់ដែលប្រើប្រាស់ទឹកពីប្រព័ន្ធតែមួយត្រូវតែបង្កើត ស.ក.ប.ទ ។ ច្បាប់នេះ ស.ក.ប.ទ មានភាពសកម្មផងដែរ ដែលឈានទៅបង្កើតឡើងតាមគំនិតផ្តួចផ្តើមនៃក្រសួងធនធានទឹក និង ឧតុនិយម ។ ល័ក្ខខ្តិកៈនៃ

ស.ក.ប.ទ មួយនឹងត្រូវចុះបញ្ជីជាមួយ ក្រ.ធ.ទ.ឧ ។ ថ្ងៃ ខែ នៃការចុះបញ្ជីសហគមន៍នឹងត្រូវបានសំរេចពីតួនាទីទាំងអស់របស់ខ្លួន ។ ដំណើរការសំរាប់ការបង្កើត ការចាត់ចែងតួនាទី និង អាណត្តិនៃ ស.ក.ប.ទ នឹងត្រូវកំណត់ច្បាស់លាស់ដោយប្រើប្រាស់អនុក្រិត្យ ។

27. សេវាផ្សព្វផ្សាយកសិកម្ម គឺជាការចាត់ចែងដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (MAFF) ។ ផ្នែកផ្សព្វផ្សាយកសិកម្មនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខេត្តតាកែវ មានបុគ្គលិក 32 រូប និងរួមបញ្ចូលដោយផ្នែកផងដែរ ព្រមទាំងភ្នាក់ងារផ្សព្វផ្សាយមកពីស្រុកចំនួន 10 របស់ខេត្តផងដែរ ។

28. សេវាឥណទានខ្នាតតូចដោយអង្គការក្រៅរដ្ឋាភិបាល (NGOs) មានភាពទូលំទូលាយនៅក្នុងតំបន់សិក្សា ។ អត្រាការប្រាក់នៃឥណទានខ្នាតតូចមានភាពផ្សេងៗគ្នារវាងពី 2% - 6% ក្នុង1ខែ អាស្រ័យលើគោលបំណង និងលក្ខខ័ណ្ឌទាំងឡាយ ។

29. ក្នុងខណៈដែលពួកគេត្រូវការប្រាក់សំរាប់ជីវភាពប្រចាំថ្ងៃ កសិករភាគច្រើនលក់ស្រូវ ឬ អង្ករ របស់ពួកគេទៅឱ្យអ្នកប្រមូលទិញភ្លាមៗបន្ទាប់ពីការប្រមូលផល និងរក្សាមួយចំនួនតូចសំរាប់បរិភោគក្នុងគ្រួសារ ។ កសិករភាគច្រើនលក់ស្រូវរបស់គេទៅឱ្យឈ្មួញកណ្តាលដោយផ្ទាល់ ឬ ទៅអោយរោងម៉ាស៊ីនកិនស្រូវ ឬក៏អ្នកទទួលទិញក្នុងទីផ្សារ ។

30. មូលដ្ឋានសំខាន់នៃផ្នែកសហគមន៍ នៅក្នុងតំបន់ជនបទ គឺភូមិដែលជាការប្រមូលផ្តុំនូវចំនួនគ្រួសារពី 100-150 ។ ឃុំគឺជាផ្នែករដ្ឋបាលបឋមនៅក្នុងប្រទេស ជាទូទៅមានប្រមាណពី 10-12 ភូមិ ។ វាមើលទៅដូចជាភាគច្រើននៃការរស់នៅរបស់ប្រជាជននៅតំបន់ជនបទ មានការចាប់អារម្មណ៍ខ្ពស់ចំពោះភូមិរបស់គេជាងឃុំរបស់ពួកគេ ។

31. ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ទទួលខុសត្រូវសំរាប់ការអភិវឌ្ឍន៍ជនបទនៅក្នុងប្រទេសកម្ពុជា ។ ដើម្បីការងារនេះ MRD កំពុងអនុវត្តន៍កម្មវិធីសិលា (ដំណាក់កាល II 2001-2005) ដែលកម្មវិធីមានគោលដៅសំខាន់ៗដូចជា : i) ពង្រឹងនូវភាពជាម្ចាស់ការនៃការគ្រប់គ្រងនៅក្នុងតំបន់ និងអភិបាលកិច្ច និង ii) កាត់បន្ថយភាពក្រីក្រក្នុងតំបន់ជនបទតាមរូបភាពវិមជ្ឈការ និង ការពង្រាយកំលាំង (Deconcentration) ។ ផែនការនៃការអភិវឌ្ឍន៍ទៅលើការរៀបចំហេដ្ឋារចនាសម្ព័ន្ធជនបទដោយឃុំ គឺជាការវាយតំលៃ និងកំណត់ និងធ្វើហិរញ្ញកិច្ចប្រសិនបើអនុម័តដោយក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ។

32. ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) កំពុងលើកទឹកចិត្តដល់ការបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍ភូមិ (VDC) និងក្រុមប្រឹក្សាអភិវឌ្ឍន៍ជនបទឃុំ (CRDC) នៅក្នុងភូមិ និង ឃុំនីមួយៗដើម្បីអនុវត្តកម្មវិធីសិលា ។ នៅក្នុងតំបន់សិក្សា VDC មួយជាទូទៅមានសមាជិក 5 រូប ដែលក្នុងនោះស្រីពីររូប ។ ដោយឡែក VDC ខ្លះមានសមាជិក 3 រូប ក្នុងនោះស្រីមួយរូប ហើយដែលនៅក្រោម VDC មានក្រុមកសិករសំរាប់សេវាឥណទាន សេវាផ្សព្វផ្សាយកសិកម្ម និង សេវាផ្សេងៗទៀតបានត្រូវបង្កើតឡើង ។

## II-2 គោលដៅនៃការអភិវឌ្ឍន៍

33. ភាគច្រើននៃគ្រួសារទាំងអស់នៅក្នុងតំបន់សិក្សា អាស្រ័យដោយប្រាក់ចំណូលពីសកម្មភាពស្រែចំការ ដែលជាប្រពៃណីតែមួយនៃការផលិតស្រូវ គឺក្រោមលក្ខខ័ណ្ឌនៃទឹកភ្លៀង ។ ចំនួនតិចតួចនៃស្រូវដែលប្រមូលបាន ត្រូវបានរក្សាទុកសំរាប់បរិភោគក្នុងគ្រួសារ និងភាគច្រើន គឺលក់ភ្លាមៗដើម្បីយកប្រាក់សំរាប់តំរូវការក្នុងផលិតកម្ម និងការរស់នៅប្រចាំថ្ងៃ ។ បន្ទាប់ពីរក្សាទុកស្រូវ ស្រូវត្រូវបានបរិភោគ ក៏ប៉ុន្តែគ្រួសារខ្លះត្រូវការទិញអង្ករពីផ្សារក្នុងតំបន់ ឬ ពីកសិករជិតខាង ។ ដើម្បីនឹងទទួលបាននូវប្រាក់ចំណូលបន្ថែម ការចិញ្ចឹមសត្វ និងដាំដំណាំកំរៃត្រូវបានអនុវត្តន៍នៅក្នុងតំបន់ ក៏ប៉ុន្តែកំរិតនៃផលិតកម្ម និងប្រាក់ចំណូលនៅតែតិចដដែល ។ បញ្ហាបីដែលបណ្តាលឱ្យលក្ខខ័ណ្ឌនៃការរស់នៅរបស់កសិករមានកំរិតទាបបានរៀបចំឡើងទៅលើ បុព្វហេតុចំបងទាំងអស់ និង កំរិតអនុភាពព្រមទាំងជាការកំណត់ ដែលលក្ខខ័ណ្ឌនៃការរស់នៅរបស់កសិករទាប គឺបណ្តាលមកពីបុព្វហេតុចំបងដោយ :

1- ការខ្វះខាតស្បៀង ( ស្រូវ)

2- ប្រាក់ចំណូលពីកសិដ្ឋានទាប អាស្រ័យជាចំបងបណ្តាលមកពីពុំមានទឹកស្រោចស្រព និងមានការយល់ដឹងពុំល្អលើការបង្កើនឡើងនូវគ្រប់បច្ចេកទេសកសិកម្ម ។ ដើម្បីដោះស្រាយបញ្ហានេះគោលដៅនៃការអភិវឌ្ឍន៍ទាំងឡាយត្រូវបានសិក្សា ដូចជាការពុំមានធនធានទឹក ការខូចខ្ទេចខ្ទាំ នូវសំណង់ស្រោចស្រពដែលមានស្រាប់ និងគ្មានការបង្កើតឡើងនូវ ស.ក.ប.ទ នៅក្នុងតំបន់សិក្សា ( មើល **Figure II-2.2.1**) ។

## II-3 សក្តានុពលនៃធនធានទឹក

34. ក្រោមលក្ខខ័ណ្ឌនៃអាងទឹកដែលមានស្រាប់ទាំងអស់ ការធ្វើការស្តារជួសជុល គឺកសាងឡើងវិញទៅតាមកំរិតនាពេលបច្ចុប្បន្ន ឬ កំរិតធម្មតា ជំរើសទាំង 12 នៃធនធានទឹក ឬក៏អាងទឹក ឬក៏ផែនការផ្គត់ផ្គង់បានត្រូវសិក្សានៅក្នុងការពិចារណាដែល :

1- ការប្រមូលផ្តុំនូវអាងទឹកទាំងអស់ដើម្បីធ្វើការអភិវឌ្ឍន៍

2- កំពស់ទំនប់ទាំងអស់

3- ផ្លូវនៃប្រលាយផ្គត់ផ្គង់ទឹកទាំងអស់ ( ប្រលាយភ្ជាប់) ( បង្ហាញក្នុង **Figure II-4.2.1**)

ការសិក្សានេះបានប្រព្រឹត្តទៅជាមួយនឹងភាពដែលអាចទុកចិត្តបានក្នុងការស្រោចស្រព 80% (Irrigation Dependability 80%) និងការអនុវត្តន៍វិធីសាស្ត្រ ការស្រោចស្រពដោយលក្ខណៈសន្សំទឹក (Water saving irrigation method) ដែល ក្រ.ធ.ទ.ឧ និងអ្នកទទួលផលចង់បានយ៉ាងខ្លាំងដើម្បីពង្រីកផ្ទៃដីស្រោចស្រពជាមួយទឹកស្រោចស្រពដែលមានមិនច្រើន ( មើល **Figure II-3.2.1** និង **Figure II-3.2.2**) ។ ការគណនាក្នុងការសិក្សាបានធ្វើឡើងតាមតុល្យភាពទឹកនៃលំហូររបស់អាងទឹកទាំងអស់ និងលទ្ធភាពស្រោចស្រពសំរាប់រយៈពេល 20 ឆ្នាំ ។

## II-4 ប្លង់មេ

35. គោលបំណងទាំងអស់នៃគំរោងប្លង់មេគឺ :

1 - បង្កើនប្រាក់ចំណូលកសិដ្ឋាន

2 - លើកកំពស់លក្ខខ័ណ្ឌនៃការរស់នៅដែលមានកំរិតទាបនាពេលបច្ចុប្បន្នក្នុងតំបន់សិក្សា ដើម្បីបានសំរេចក្នុងការកាត់បន្ថយភាពក្រីក្រ និង ធ្វើឱ្យមានស្ថេរភាពស្បៀងក្នុងតំបន់សិក្សា ។ លើសពីនេះទៀតការកំណត់ស្នើផែនការអភិវឌ្ឍន៍នៅក្នុងគំរោងផែនការមេនឹងជាគំរូសំរាប់ជាមូលដ្ឋានស្រោចស្រពនៃការស្តារ និង សាងសង់ឡើងវិញនូវប្រព័ន្ធផលិតផលកសិកម្មនៅក្នុងប្រទេសកម្ពុជា ។

36. គំនិតមូលដ្ឋាននៃការអភិវឌ្ឍន៍បានប្រើប្រាស់ដើម្បីបង្កើតឡើងនូវផែនការមេដែលមានជាបន្តបន្ទាប់ :

1 - ដើម្បីប្រសិទ្ធិភាពការប្រើប្រាស់ទឹក និង ធនធានដីសំរាប់និរន្តភាពនៃការអភិវឌ្ឍន៍

2 - ដើម្បីស្តារជួសជុលឡើងវិញនូវអាងទឹកដែលមានស្រាប់ទាំងអស់ និងសំណង់ស្រោចស្រពទាំងឡាយដោយប្រើលទ្ធភាពបច្ចេកទេសដោយការសាងសង់ថ្មីមួយក្នុងកំរិតតូច ។

3 - ដើម្បីសាងសង់ស្រះទឹកជិតស្រែក្បែរផ្ទះ និងប្រើប្រាស់ប្រលាយស្រាប់ជាស្រះទឹក ដើម្បីផ្តល់ដល់ការស្រោចស្រព ប្រើប្រាស់ក្នុងលំនៅដ្ឋាន និងការចិញ្ចឹមត្រី ។

4 - ដើម្បីបង្កើនការធ្វើកសិកម្មស្រូវបច្ចុប្បន្នសំរាប់ស្ថេរភាព ការផ្គត់ផ្គង់អង្ករក្នុងតំបន់ ដោយការស្រោចស្រពបង្កើនពូជធារ និង ពង្រឹងការងារស្រែចំការ ។

5 - ដើម្បីចាប់ផ្តើមការដាំដុះដំណាំកំរៃ ដូចជា សណ្តែក បន្លែ ដំណាំយកប្រេង ព្រមទាំងការចិញ្ចឹមសត្វដូចជាជ្រូក គោ សំរាប់បង្កើនប្រាក់ចំណូលកសិកម្ម និងលើកកំពស់នូវអាហារូបត្ថមដល់កសិករ ។

6 - ដើម្បីបង្កើនឡើងនូវកម្មវិធីទាំងឡាយ ដើម្បីគាំទ្រដល់ការងារកសិកម្មសំរាប់ការធ្វើឱ្យប្រាកដឡើងនិងពង្រីកការស្រោចស្រពព្រមទាំងអានុភាពនៃការអភិវឌ្ឍន៍កសិកម្ម និង ធ្វើឱ្យប្រាកដផងដែរនូវប្រព័ន្ធកសិកម្មនិរន្តភាពដោយកសិករខ្លួនឯងផ្ទាល់ដូចជា :

- ការបង្កើតក្រុមកសិករនៅកំរិតភូមិ និងការបណ្តុះបណ្តាលអ្នកដឹកនាំក្រុមកសិករ
- សេវាផ្សព្វផ្សាយកសិកម្ម
- សេវាតណទានខ្នាតតូច
- បង្កើនឡើងនូវទីផ្សារផលិតផលកសិកម្ម

7 - ពង្រីកឡើងនូវផ្លូវជនបទ និង កសិដ្ឋាន ដើម្បីពង្រីកនូវការធ្វើកសិកម្មទីផ្សារ និងបង្កើតឡើងនូវសកម្មភាពដទៃទៀតសំរាប់ក្រុមកសិករ និង ស.ក.ប.ទ ។

8 - ដើម្បីបង្កើតឡើងនូវ ស.ក.ប.ទ ដែលមាននិរន្តភាពតាមរយៈការចូលរួមពីអ្នកដែលបានទទួលផល និងសមត្ថភាពនៃការកសាងសមត្ថភាពដល់បុគ្គលិកការិយាល័យគំរោងនៃ ក្រ.ធ.ទ.ឧ សំរាប់ការអនុវត្តគំរោង ។

9 - ដើម្បីអភិរក្សបរិដ្ឋានដែលមិនធ្វើឱ្យមានការប៉ះពាល់ជាអវិជ្ជមានក្នុង និងជុំវិញតំបន់សិក្សា ។

37. គោលដៅជាចំបងសំរាប់ការស្តារ ជួសជុល និងកសាងឡើងវិញនូវប្រព័ន្ធផលិតផលកសិកម្មក្នុងតំបន់អាងទឹកស្ទឹងស្លាគូ គឺជាការកំណត់នូវធនធានទឹកទាំងឡាយដើម្បីបង្កើននូវផលិតកម្ម និងលើកកំពស់ផលិតផលដីទៃទៀត ។ យោងលើធនធានទឹកដែលមានបច្ចុប្បន្ន វិធីសាស្ត្រអភិវឌ្ឍន៍ជាបន្តបន្ទាប់បី គឺជាផែនការដែលត្រូវស្នើរបញ្ចូលទៅលើការអភិវឌ្ឍន៍ការស្រោចស្រពជាមូលដ្ឋាននៅក្នុងតំបន់ដូចជា :

1- ផែនការសាងសង់ឡើងវិញប្រព័ន្ធស្រោចស្រពនៅផ្នែកខាងលើស្ទឹងស្លាគូ (USP)

2- ផែនការស្តារជួសជុលឡើងនូវអាងតូចៗ (SRP)

3- ផែនការអភិវឌ្ឍន៍ស្រះតូចៗ (PDP)

ក្នុងករណីនេះដើម្បីធ្វើឱ្យប្រាកដ និងពង្រីកឡើងនូវផលប្រយោជន៍ ការអភិវឌ្ឍន៍ ការស្រោចស្រពជាមូលដ្ឋានខាងលើកម្មវិធីគាំទ្រជាបន្តបន្ទាប់គឺ :

i) កម្មវិធីពង្រីកផ្លូវជនបទ

ii) កម្មវិធីផលិតផលកសិកម្ម

iii) កម្មវិធីគាំទ្រដល់ការងារកសិកម្ម

iv) កម្មវិធីអភិវឌ្ឍន៍ស្ថាប័ន

v) កម្មវិធីអភិរក្សបរិស្ថាន

ទំនាក់ទំនងរវាងផែនការនៃការស្តារជួសជុល និងកសាងឡើងវិញនូវការស្រោចស្រពជាមូលដ្ឋាន និងកម្មវិធីគាំទ្របានបង្កើតឡើងដូចតទៅ ( មើល **Figure II-4.1.1**)

**ទំនាក់ទំនងរវាងផែនការ និង កម្មវិធីគាំទ្រ**

| កម្មវិធីគាំទ្រ | ផែនការការអភិវឌ្ឍន៍ការស្រោចស្រពជាមូលដ្ឋាន | | |
|---|---|---|---|
| | USP | SRP | PDP |
| ការពង្រីកផ្លូវជនបទ និង កសិដ្ឋាន | ○ | ○ | ○ |
| ផលិតផលកសិកម្ម | ○ | ○ | ○ |
| ការគាំទ្រដល់កសិកម្ម | ○ | ○ | ○ |
| ការអភិវឌ្ឍន៍បរិស្ថាន | ○ | ○ | ○ |
| ការអភិរក្សបរិស្ថាន | ○ | ○ | △ |

○ : តំរូវការ △ : តំរូវការមានកំណត់

38. ការប្រកាន់យកនូវរយៈកាលនៃផែនការអភិវឌ្ឍន៍ 5 ឆ្នាំ លើកទី 2 (2001-2005) និងការចូលរួមនៃសមភាគរបស់ផែនការមេទៅក្នុងការពិចារណា ដែលរយៈកាលនៃផែនការមេបានកំណត់ចាប់ពី ឆ្នាំ 2001 រហូតដល់ ឆ្នាំ 2010 សំរាប់រយៈពេល 10 ឆ្នាំ ។

39. រាជរដ្ឋាភិបាលកម្ពុជាបានប៉ាន់ប្រមាណថា អត្រាកំណើនពលរដ្ឋប្រចាំឆ្នាំនឹងមានកំរិតខ្ពស់គឺ 2,4% សំរាប់ឆ្នាំ 2000 ដែលកើនឡើង 1,33 ដងនៃពលរដ្ឋឆ្នាំ 1998 ។ ដើម្បីធានាបាននូវសុវត្ថិភាពនៃបរិមាណតំរូវការតុល្យភាពបច្ចុប្បន្ន និងការផ្គត់ផ្គង់អង្ករនៅក្នុងតំបន់សិក្សាតំរូវការផលិតកម្មស្រូវ នឹងត្រូវកើនឡើង 2,4% ក្នុង 1 ឆ្នាំ ។ បរិមាណតំរូវការស្រូវនៅក្នុងតំបន់សិក្សានៅក្នុង ឆ្នាំ 2010 បានប៉ាន់ស្មានប្រមាណ 64.600 តោន ។

40. ការប្រើប្រាស់ដីនៅក្នុងផែនការមេ បានកំណត់ជាកំលាក់អំពីដីប្រើប្រាស់បច្ចុប្បន្ន ដែលបង្ហាញខាងក្រោមនេះ :

**ផែនការប្រើប្រាស់ដី**

(ឯកតា : ហ.ត)

| | ផ្ទៃដីដាំដុះ | ព្រៃឈើ ដីដំណាំកសិផល | ព្រៃគុម្ពោត ព្រៃបាះ | ដីលំនៅដ្ឋាន | សរុប |
|---|---|---|---|---|---|
| បច្ចុប្បន្ន | 44,240 | 4,370 | 9,130 | 7,260 | 65,000 |
| កំណត់សំណើ | 43,000* | 7,000 | 5,000 | 10,000 | 65,000 |
| សមតុល្យ | -1,240 | 2,630 | -4,130 | 2,740 | 0 |

* : ដីវាលស្រែ 40,000 ហ.ត ដីដំណាំរដូវប្រាំង 3,000 ហ.ត

41. **ផែនការសាងសង់ឡើងវិញប្រព័ន្ធស្រោចស្រពនៅផ្នែកខាងលើស្ទឹងស្លាគូ** (USP):

ជំរើសទាំងអស់នៃការត្រួតពិនិត្យ គឺបានប៉ាន់ស្មានទៅលើតំបន់ និងផលប្រយោជន៍បច្ចេកទេសត្រឹមត្រូវ ការប៉ះពាល់ជាអវិជ្ជមានការតាំងចិត្តរបស់រដ្ឋាភិបាល ព្រមទាំងការតាំងចិត្តរបស់អ្នកទទួលផល ។ ដែលជាលទ្ធផលជំរើស 3-1 (ខ្ពបត្របែក + ទំនប់លោកទាប) ត្រូវបានកំណត់ស្នើជាជំរើសដ៏ល្អនៃការអភិវឌ្ឍន៍ ។ ផ្ទៃដីស្រោចស្រពគឺសរុប 3.500 ហ.ត (មើល **Figure II-4.2.2**)

42. **ផែនការជួសជុលឡើងវិញអាងតូចៗ** (SRP):

នៅក្នុងតំបន់សិក្សាមានអាងតូចៗចំនួន 36 ដែលបាន ចុះបញ្ជីហើយដែលភាគច្រើនសាងសង់ឡើងក្នុងសម័យប៉ុលពត ។ ក្នុងខណៈដែលមានពត៌មានបច្ចេកទេសតិចតួចអំពីអាងទឹកតូចៗទាំងនេះ ការសិក្សាស្ទាបស្ទង់អង្កេតបានប្រព្រឹត្តទៅដោយបច្ចេកទេសនៃការវាយតំលៃ និងមធ្យោបាយសេដ្ឋកិច្ចដែលមានអាស្រ័យលើប្រភពទឹកដែលមានបរិមាណប៉ាន់ស្មាន ហើយនិងសេចក្តីបញ្ជាក់នៃការតាំងចិត្តរបស់ពួកអ្នកទទួលផល ។ ជាលទ្ធផលការស្តារជួសជុលឡើងវិញនូវអាងទឹកតូចៗចំនួន 15 ជាមួយនិងផ្ទៃដីសរុបប្រមាណ 280 ហ.ត ត្រូវបានកំណត់ស្នើរឡើងទៅតាមមធ្យោបាយបច្ចេកទេស និង សេដ្ឋកិច្ចនៃផែនការស្តារជួសជុលឡើងវិញ (មើល **Table II-4.3.3**) ។ ចំនួនផ្សេងទៀតក្នុងចំណោមអាងទឹកទាំងនោះដែល :

1- អាងទំនប់ កំសី ក្នុងឃុំញ៉ែងញ៉ង

2- អាងទឹក អាង 160 ក្នុងឃុំត្រពាំងធំខាងត្បូង

អាងទឹកទាំងពីរនេះបានចង្អុលបង្ហាញជាមួយអាទិភាពខ្ពស់ ដែលជាផែនការស្តារជួសជុលឡើងវិញដំបូងគេ ។ ផ្ទៃដីស្រោចស្រពនៃអាងទាំងពីរនេះគឺសរុប 42 ហ.ត ។

43. **ផែនការអភិវឌ្ឍន៍ស្រះតូចៗ** (PDP):

ធនធានទឹកនៃស្ទឹងទាំងឡាយក្នុងតំបន់សិក្សាវាមានកំរិត ។ សំរាប់តំបន់ក្រៅ USP និង SRP ប្រភេទទឹកគឺទឹកភ្លៀង និងទឹកដែលបង្ហូរពីតំបន់ផ្នែកខាងលើ ។ ដើម្បីជាមធ្យោបាយសំរាប់រក្សាទុក និងប្រើប្រាស់គឺការសាងសង់ស្រះទឹក និងប្រើប្រាស់ប្រលាយដែលមានស្រាប់ជាស្រះទឹក ។ ស្រះទឹកបីប្រភេទត្រូវបានកំណត់

ស្នើឡើងជាផែនការអភិវឌ្ឍន៍ស្រះតូចៗ (PDP) ដែល :

1- ស្រះទឹកតូចដែលប្រើប្រាស់ដោយក្រុមកសិករ

2- ស្រះទឹកតូចដែលប្រើប្រាស់ជាលក្ខណៈឯកជន

3- ស្រះទឹកតូចដែលធ្វើក្នុងប្រឡាយដែលមានស្រាប់ ។ ( មើល **Figure II-4.4.1, II-4.4.2** និង **Figure II-4.4.3**) បំណងសំខាន់ក្នុងការផ្តល់ស្រះនេះ គឺសំរាប់គ្រប់គ្រួសារ ( ប្រមាណ 250 ភូមិ) ដែលស្ថិត នៅខាងក្រៅ USP និង SRP ។ PDP ជាមួយនឹងការសាងសង់ស្រះចំនួន 72 ក្នុងមួយភូមិ គឺកំណត់ស្នើឡើង សំរាប់រយៈពេល 10 ឆ្នាំ ។ ដែលជាគំរោងគំរូមួយនៃ PDP នៅក្នុងភូមិមួយនៃឃុំញ៉ៀងញ៉ង ត្រូវបានកំណត់ ស្នើឡើងសំរាប់ជាការសិក្សាដំបូង ។

44. **កម្មវិធីផលិតកម្មកសិកម្ម:**

ដើម្បីសំរេចនូវគោលដៅទាំងនេះនៃផែនការមេ ដំណាំសំណើដាំដុះសំរាប់ផែនការអភិវឌ្ឍន៍ការស្រោចស្រពបីត្រូវបានជ្រើសរើស ដែលបង្ហាញខាងក្រោម ( មើល **Figure II-4.5.1**):

**ដំណាំជ្រើសរើសនៃផែនការអភិវឌ្ឍន៍ចំនួនបី**

| ផែនការ | ស្រូវ | ដំណាំរួមផ្សំ |
|---|---|---|
| 1. ផែនការសាងសង់ឡើងវិញប្រព័ន្ធស្រោចស្រពនៅផ្នែកខាងលើ ស្ទឹងស្លាគូ (3,500 ហ.ត) | HYVs (ស្រូវដើមឆ្នាំ ពពូកស្រូវ IR) និងការបង្កើនពូជស្រូវក្នុងស្រុក ( ពូជស្រូវកណ្តាល) | ពោត សណ្តែក ( សណ្តែកបាយ សណ្តែកសៀង) សណ្តែកដី ល្ង និង បន្លែ ( ត្រសក់ ប៉េងប៉ោះ គ្រប់ សណ្តែកកួរ ឪឡឹក ល្ពៅ ល្ពៅខ្សែ ម្ទេស ។ល។ ) |
| 2. ផែនការស្តារជួសជុលឡើងវិញអាងតូចៗ (280 ហ.ត) | | |
| 3. ផែនការអភិវឌ្ឍន៍ស្រះតូចៗ (2,100 ហ.តនៃដី 39,220 ហ.ត) | HYVsរឺបង្កើនពូជក្នុងស្រុក( ស្រូវកណ្តាល) ក្រោមលក្ខខ័ណ្ឌនៃទឹកភ្លៀង | សណ្តែក ( សណ្តែកបាយ សណ្តែកសៀង) សណ្តែកដី ល្ង និង បន្លែ ( ត្រសក់ ប៉េងប៉ោះ គ្រប់ សណ្តែកកួរ ឪឡឹក ល្ពៅ ល្ពៅខ្សែ ម្ទេស ។ល។ ) |

មូលដ្ឋានសំរាប់ជំរើសខាងលើមានដូចតទៅ :

i) ដើម្បីរក្សាទុកប្រព័ន្ធការងារស្រែចំការជាមូលដ្ឋាន ដើម្បីនឹងសំរេចឱ្យបាននូវស្បៀងគ្រប់គ្រាន់សំរាប់ប្រជាជនក្នុងតំបន់សិក្សា និងការដាំស្រូវនៅក្នុងរដូវវស្សា ។

ii) ដើម្បីនឹងចាប់ផ្តើមការដាំដំណាំរួមផ្សំ មុន ឬក៏ក្រោយការធ្វើស្រែជាមួយនឹងការពង្រីកទឹកស្រោចស្រពដែលមាន គឺដើម្បីនឹងបង្កើនប្រាក់ចំណូលរបស់កសិករទាំងអស់ ។

iii) ដើម្បីជ្រើសរើសដំណាំរួមផ្សំ ដែលសមស្របតាមការពិនិត្យនៃភាពសមរម្យតាមលក្ខខ័ណ្ឌធម្មជាតិ ផលប្រយោជន៍ដែលមាន និងទីផ្សារផលិតផលដែលអាចមានរួមបញ្ចូលនឹងបរិមាណផលិតកម្មសំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្មក្នុងប្រទេសកម្ពុជា និងរូមផ្សំគឺតបច្ចុប្បន្ននៃបច្ចេកទេសការងារស្រែចំការរបស់កសិករ ។

45. ផ្ទៃដីស្រោចស្រពនៃផែនការអភិវឌ្ឍន៍ចំនួនបីគឺសរុប 5.880 ហ.ត ដែលផែនការនេះគ្របដណ្តប់គ្រប់ភូមិទាំងអស់ ព្រមទាំងគ្រួសាររបស់កសិករនៅក្នុងតំបន់សិក្សាស្រោចស្រពផ្នែកខាងលើស្ទឹងស្លាគូ (USP) ផែនការស្តារជួសជុលឡើងវិញអាងតូចៗ SRP និងផែនការអភិវឌ្ឍន៍ស្រះតូចៗ (PDP) បានប៉ាន់ស្មានជាបន្តបន្ទាប់ 4.500 1.400 និង 30.000 គ្រួសារ ។

46. ក្រោមការស្តារជួសជុល និង កសាងឡើងវិញនូវសំណង់ស្រោចស្រពទាំងអស់ ព្រមទាំងកំណត់ស្នើគំរូដាំដុះ ការអភិវឌ្ឍន៍ខ្លះៗគឺ :

1- ការអនុវត្តន៍ការងារស្រែចំការ

2- ការប្រើប្រាស់ធនធានស្រែចំការ

3- ការចិញ្ចឹមគោ ក្របី និង ជ្រូកត្រូវបានកំណត់ស្នើឡើងសំរាប់ជាលទ្ធផលនៃគោលដៅការអភិវឌ្ឍន៍ ។

ផលប្រយោជន៍នៃការស្រោចស្រពបានប៉ាន់ស្មានដូចតទៅ :

**កំណើនប្រាក់ចំណូលដែលប៉ាន់ស្មាន**

(ឯកតា : លានរៀល)

| ផែនការ | ចំណូលសរុប | ផលប្រយោជន៍ | ផលកើន | កំណត់សំគាល់ |
|---|---|---|---|---|
| កសិករមានដីមធ្យម | | | | |
| 1. USP | 1.52 | 1.06 | 0.83 | កសិករមានដីមធ្យម: 0.8 ហ.ត/គ្រួសារ |
| 2. SRP | 1.52 | 1.06 | 0.82 | |
| 3. PDP | 0.48 | 0.31 | 0.07 | ផ្ទៃដីស្រោចស្រព: 0.07 ហ.ត/គ្រួសារ |

47. **កម្មវិធីពង្រីកផ្លូវជនបទ :**

ផ្លូវនៅក្នុងតំបន់សិក្សាដើរតួនាទីសំខាន់ដូចជា :

1- ការធ្វើដំណើរចាំបាច់ក្នុងការរស់នៅ

2- ផ្លូវកសិដ្ឋានដើម្បីដឹកជញ្ជូនឧបករណ៍កសិកម្ម

3- ផ្លូវទីផ្សារដើម្បីដឹកជញ្ជូនផលិតផលកសិកម្មទៅកាន់ទីផ្សារ ។

ដើម្បីនឹងរៀបចំពង្រីកផ្លូវជនបទ គ្រប់ផ្លូវទាំងអស់ក្នុងតំបន់សិក្សាបានចាត់ជាបីប្រភេទគឺ :

1-ផ្លូវធំ

2-ផ្លូវមធ្យម និង

3-ផ្លូវភ្ជាប់ទៅផ្លូវធំ និង ផ្លូវមធ្យម

សរុបផ្លូវទាំងអស់មាន 154,3 គម បានវាយតំលៃយោងទៅលើតំបន់គ្របដណ្តប់ លក្ខខ័ណ្ឌបច្ចុប្បន្នក៏រិតនៃសារៈសំខាន់ និងអាទិភាពសំរាប់ការស្តារជួសជុលឡើងវិញនៃផ្លូវទាំងនេះ ។ ក្រៅពីផ្លូវអាទិភាពទីមួយទាំងនេះ ផ្លូវបីបន្តបន្ទាប់ទៀតដែលមានប្រវែងសរុប 24,5 គម គឺបានចាត់ទុកជាអាទិភាពខ្ពស់ជាងគេ (មើល **Figure II-4.6.2**)

1) ពីត្រពាំងធំខាងជើងទៅត្រពាំងក្រញូង (13 គម)

2) ពីអូរសារ៉ាយទៅផ្លូវស្ទឹងស្លាគូ (5,5 គម)

3) ផ្លូវខ្ពបស្វាយ (6 គម)

48. **កម្មវិធីគាំទ្រកសិកម្ម :**

កម្មវិធីទាំងឡាយដែលគាំទ្រដល់កសិកម្មក្រោមផែនការមេដែលមានគឺ :

1- ក្រុមកសិករ (FGs) នៅកំរិតភូមិ

2- ការផ្សព្វផ្សាយសេវាកម្ម

3- សេវាឥណទាន

4- ផលិតផលកសិកម្ម និង ទីផ្សារ

(1) **ក្រុមកសិករ (FGs) នៅកំរិតភូមិ :** ដើម្បីនឹងគាំទ្រទៅដល់ផែនការស្តារជួសជុល និង កសាងឡើងវិញនូវការស្រោចស្រពជាមូលដ្ឋាន ស្ថាប័នមួយនៃក្រុមកសិករដែលមានតួនាទីក្រោម VDC គឺជាការចាំបាច់ ។ ស្របគ្នាជាមួយនឹងពតិមាននៃក្រុមកសិករ ស.ក.ប.ទ មួយ នឹងត្រូវបង្កើតឡើង ។ ការបង្កើត VDC និងក្រុមកសិករបានស្នើរដើម្បីអនុវត្តន៏សេវាឥណទាន សេវាផ្សព្វផ្សាយ ។ល។

(2) **សេវាផ្សព្វផ្សាយកសិកម្ម និង ការបង្កាត់ពូជសត្វ :** កម្មវិធីបង្កើនសេវាផ្សព្វផ្សាយកសិកម្មរួមបញ្ចូលនិង :

- ការធ្វើស្រែបង្ហាញ
- ក្រុមលក់ដូរឧបករណ៍កសិកម្ម
- ការបណ្តុះបណ្តាលភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ (VEWs) ក្នុងកំរិតភូមិចំពោះអ្នកដែលជាប្រធានក្រុមកសិករ ដើម្បីនិងបង្កើតឡើងនូវពូជស្រូវច្រើនប្រភេទដែលបានកំណត់ស្នើឡើង ។

(3) **សេវាឥណទាន :** តំលៃស្រូវនាពេលអនាគតនឹងកើនឡើងពី ពីរ ទៅ បីដង នៃតំលៃបច្ចុប្បន្ន ។ បរិមាណនៃចរន្តហិរញ្ញវត្ថុរបស់កសិករ គឺមានការខ្វះខាតសំរាប់វិនិយោគសមរម្យនៃទុនកសិកម្ម ។ ដើម្បីនឹងសំរេចគោលដៅទាំងនេះ កម្មវិធីប្រព័ន្ធឥណទានកសិកម្ម គឺជាការសំខាន់សំរាប់កសិករទាំងអស់ ។ កិច្ចព្រួតដៃគ្នារវាង NGOs និងស្ថាប័ននៃក្រុមកសិករឥណទានក្រោម VDC ត្រូវបានកំណត់ស្នើឡើង ។

(4) **ដំណើរការផលិតផលកសិកម្ម និង ទីផ្សារ :** ដើម្បីនឹងប្រព្រឹត្តទៅនៃ :

- ការប្រមូលផ្តុំ និង ទីផ្សារផលិតផលដំណាំ
- ទីផ្សារនៃស្រូវរបស់ ស.ក.ប.ទ ដែលបានមកពីថ្លៃសេវាស្រោចស្រពទឹក (ISF) វាជាការកំណត់សំណើឡើងក្នុងប្លង់មេដើម្បីបង្កើតឡើងក្រុមទីផ្សារ ។ សកម្មភាពទាំងអស់នៃក្រុមកសិករ វាមានផលប្រយោជន៍ច្រើនយ៉ាងសំរាប់ពង្រីកនូវកន្លែងប្រមូលផល និង សកម្មភាពទីផ្សារតាមរយៈសកម្មភាពផ្សព្វផ្សាយប្រសិទ្ធិភាព ការបង្កើត ការប្រកួតប្រជែង និងបង្កើនឡើងនូវអានុភាពកិច្ចព្រមព្រៀងតំលៃលក់ដូរ ។

49. **សមាគមកសិករប្រើប្រាស់ទឹក ( ស.ក.ប.ទ)**

រាជរដ្ឋាភិបាលកម្ពុជាបានចេញសារាចរលេខ 01 ដើម្បីអនុវត្តន៍ទៅលើនយោបាយសំរាប់និរន្តរភាពនៃប្រព័ន្ធស្រោចស្រពនៅខែ មករា ឆ្នាំ 1999 អាស្រ័យដោយមូលដ្ឋានសំខាន់ៗដូចនេះ :

- តួនាទីស្របច្បាប់របស់ ស.ក.ប.ទ
- ការជាប់ទាក់ទងនៃ ស.ក.ប.ទ ក្នុងការអភិវឌ្ឍន៍ប្រព័ន្ធ
- តួនាទីរបស់កសិករក្នុងការបង់ថ្លៃប្រតិបត្តិការ និងការថែទាំ (O&M) និងតំលៃជួសជុលបន្ទាន់
- ការចាត់ចែងផ្តល់ទឹកឱ្យមានសមភាព

ការបង្កើត ស.ក.ប.ទ នៅក្នុងតំបន់សិក្សាបានកំណត់ស្នើឡើងដោយមានចំណងរចនាសម្ព័ន្ធនៃប្រព័ន្ធដូចជា :

1- គណៈកម្មាការផ្លូវទឹកក្នុងកំរិតផ្លូវទឹក

2- គណៈកម្មាការប្រលាយស្រោចស្រព ( ប្រលាយទី III) ក្នុងកំរិតប្រលាយស្រោចស្រព

3- គណៈកម្មាការប្រលាយរងក្នុងកំរិតប្រលាយរង

4- គណៈកម្មាការប្រលាយមេ ក្នុងសំណង់យកទឹក ឬ ក្បាលហុងទឹក

5- គណៈកម្មាការជាន់ខ្ពស់ក្នុងកំរិតគំរោង

50. ដើម្បីនឹងសំរេចនូវគោលបំណងទាំងអស់នេះនៃ ស.ក.ប.ទ ការបណ្តុះបណ្តាលបុគ្គលិករបស់ ស.ក.ប.ទ គឺជាការសំខាន់ ។ ក្រ.ធ.ទ.ឧ បានកំណត់ស្នើឡើងដើម្បីផ្តល់នូវការបណ្តុះបណ្តាលសំរាប់ការបង្កើត ស.ក.ប.ទ និងដំណើរការរបស់វា ដូចជាការងារបច្ចេកទេស និងការងាររដ្ឋបាលដែលចាំបាច់សំរាប់ប្រតិបត្តិការ និងការថែទាំសំណង់ស្រោចស្រពទៅដល់ពួកគេដែលជាបុគ្គលិករបស់ ស.ក.ប.ទ ។

51. **ការកសាងសមត្ថភាពរបស់ ក្រ.ធ.ទ.ឧ :**

ក្រ.ធ.ទ.ឧ នឹងបង្កើតឡើងនូវការិយាល័យគំរោងមួយ ក្នុងពេលដែលផែនការអភិវឌ្ឍន៍ត្រូវបានអនុវត្តន៍ ។ ក្នុងបច្ចុប្បន្នកាលមន្ទីរធនធានទឹកខេត្តតាកែវ មានសមត្ថភាពមិនច្រើនឡើយសំរាប់ការអនុវត្តន៍ពីព្រោះចរន្តការងារទាំងនេះវាច្រើនណាស់សំរាប់មន្ទីរ ។ ដើម្បីនឹងអនុវត្តន៍ឱ្យមានភាពរលូន ផែនការអភិវឌ្ឍន៍ទាំងអស់បានកំណត់ស្នើឡើង ឯការកសាងសមត្ថភាពជាបន្តបន្ទាប់នៃ ក្រ.ធ.ទ.ឧ ក៏ត្រូវបានកំណត់ស្នើឡើងដែរគឺ :

1- ពង្រឹងនូវសមត្ថភាពក្នុងការធ្វើផែនការ ធ្វើគំរោងការ និងគ្រប់គ្រងការសាងសង់ ។

2- តែងតាំងអ្នកជំនាញសំរាប់ ស.ក.ប.ទ និង ការងារប្រតិបត្តិ និងការថែទាំ

3- បណ្តុះបណ្តាលបុគ្គលិករបស់ការិយាល័យគំរោងអំពីការធ្វើផែនការ នៃគំរោងស្រោចស្រព ការធ្វើគំរោងការនៃសំណង់ស្រោចស្រព ត្រួតពិនិត្យការសាងសង់ និងផ្ទេរនូវប្រតិបត្តិការ និងការថែទាំទៅដល់ ស.ក.ប.ទ ។ល។

52. **កម្មវិធីអភិរក្សបរិស្ថាន** :

កម្មវិធីអភិរក្សបរិស្ថានជាបន្តបន្ទាប់ត្រូវបានកំណត់ស្មើឡើងយោងទៅលើ :

1- លក្ខខ័ណ្ឌដែលមានស្រាប់នៅក្នុង និង ក្រៅតំបន់សិក្សា

2- លក្ខណៈនៃសមភាគសំខាន់ៗនៃផែនការមេ

3- លទ្ធផលនៃការត្រួតពិនិត្យបរិស្ថានដំបូង (IEE) គឺ :

- កម្មវិធីសំរាប់ធ្វើឱ្យមានការប៉ះពាល់តិចតួច និងការត្រួតពិនិត្យការប៉ះពាល់ជាអវិជ្ជមាន (ទឹកដែលការពារពីសេចក្តីអន្តរាយ និងជំនួយដល់ការប៉ះពាល់លំនៅដ្ឋានទាំងឡាយ)

- កម្មវិធីសំរាប់និរន្តរភាពជាកំលាក់នៃបរិស្ថាន (ការគ្រប់គ្រងនីវ៉ូទឹករវាងប្រភពពីរផ្សេងគ្នា គឺតំបន់ខាងលើ និង ខាងក្រោម និងអភិរក្សធនធានព្រៃឈើ) ។

53. **កម្មវិធីអនុវត្តន៍:**

កម្មវិធីអនុវត្តន៍ទាំងឡាយនៃផែនការសាងសង់ឡើងវិញ ការស្រោចស្រពនៅតំបន់ស្ទឹងស្លាគូផ្នែកខាងលើ (USP) ផែនការស្តារជួសជុលអាងតូចៗ (SRP) និងផែនការអភិវឌ្ឍន៍ស្រះទឹកតូចៗ (PDP) គឺបង្ហាញជាបន្តបន្ទាប់ :

**ដំណាក់កាល និង រយៈពេលនៃ USP**

| | ពាក់កណ្តាលឆ្នាំ | ពាក់កណ្តាលឆ្នាំ |
|---|---|---|
| ដំណាក់កាល -1 | 800 ហ.ត | ពាក់កណ្តាលឆ្នាំ 2002 – ដើមឆ្នាំ 2006 |
| ដំណាក់កាល -2 | 2,700 ហ.ត | ចុងឆ្នាំ 2003 – ពាក់កណ្តាលឆ្នាំ 2008 |
| **សរុប** | 3,500 ហ.ត | |

**ដំណាក់កាល និង រយៈពេលនៃ SRP**

| | ពាក់កណ្តាលឆ្នាំ | ពាក់កណ្តាលឆ្នាំ |
|---|---|---|
| ដំណាក់កាល -1 | អាងទឹក 2 | ពាក់កណ្តាលឆ្នាំ 2002 – ដើមឆ្នាំ 2006 |
| ដំណាក់កាល -2 | អាងទឹក 7 | ចុងឆ្នាំ 2003 – ពាក់កណ្តាលឆ្នាំ 2008 |
| ដំណាក់កាល -3 | អាងទឹក 6 | ពាក់កណ្តាលឆ្នាំ 2006 – ដើមឆ្នាំ 2010 |

**ដំណាក់កាល និង រយៈពេលនៃ PDP**

| | ពាក់កណ្តាលឆ្នាំ | ពាក់កណ្តាលឆ្នាំ |
|---|---|---|
| ដំណាក់កាល -1 | ស្រះ 6 ក្នុងមួយភូមិ | ពាក់កណ្តាលឆ្នាំ 2002 – ដើមឆ្នាំ 2006 |
| ដំណាក់កាល -2 | ស្រះ 24 ក្នុងមួយភូមិ | ចុងឆ្នាំ 2003 – ពាក់កណ្តាលឆ្នាំ 2008 |
| ដំណាក់កាល -3 | ស្រះ 42 ក្នុងមួយភូមិ | ពាក់កណ្តាលឆ្នាំ 2006 – ដើមឆ្នាំ 2010 |
| **សរុប** | ស្រះ 72 ក្នុងមួយភូមិ | |

54. **ទំលៃគ្រោង :**

ការប៉ាន់ស្មានតំលៃគ្រោងទាំងអស់សំរាប់ USP SRP និង PDP គឺដូចតទៅ :

1- ផែនការសាងសង់ឡើងវិញនូវការស្រោចស្រពផ្នែកខាងលើស្ទឹងស្លាគូ (USP) : 71.460,1 លានរៀល

2- ផែនការស្តារជួសជុលឡើងវិញនូវអាងតូចៗ (SRP)

**តំលៃគ្រោងនៃអាងទឹកតូចៗតំបូង**

| ឈ្មោះអាងទឹក | អាទិភាព | ផ្ទៃដីស្រោចស្រព (ហ.ត)* | តំលៃគ្រោង** (ពាន់រៀល) |
|---|---|---|---|
| ទំនប់ កំសី | 1st | 21 | 395,870 |
| អាង 160 | 1st | 21 | 379,100 |
| ត្រពាំងលៀន | 3rd | 10 | 261,030 |

* : ការចុះបញ្ជីផ្ទៃដីស្រោចស្រពដោយឃុំ និង ការិយាល័យស្រុក

**: តំលៃបំរុងពុំបានគិតបញ្ចូល

3) ផែនការអភិវឌ្ឍន៍ស្រះទឹកតូចៗ (PDP)

**តំរោងតំលៃនៃការអភិវឌ្ឍន៍ស្រះទឹកតូចៗ**

| ប្រភេទស្រះទឹក | មាឌប្រសិទ្ធិភាព (ម³) | ផ្ទៃស្រោចស្រព/1ស្រះ (ហ.ត) | ចំនួនស្រះទឹក | ផ្ទៃស្រោចស្រព (ហ.ត) | តំលៃគំរោង* (ពាន់រៀល) |
|---|---|---|---|---|---|
| ស្រះទឹក (ការគ្រប់គ្រងជាក្រុម) | 846 | 0.34 | 15 | ប្រមាណ 5ហ.ត | 129,380 |
| ប្រលាយទឹក (ការគ្រប់គ្រងជាក្រុម) | 846 | 0.34 | 15 | ប្រមាណ 5ហ.ត | 97,550 |
| ស្រះទឹក (ការគ្រប់គ្រងម្នាក់ៗ) | 184 | 0.07 | 72 | ប្រមាណ 5ហ.ត | 154,830 |

*: តំលៃបំរុងពុំបានគិតបញ្ចូល ។

55. **ការវាយតំលៃគំរោង :**

ផែនការអភិវឌ្ឍន៍ការស្រោចស្រពចំនួនបីនៃ USP SRP និង PDP បានត្រូវវាយតំលៃដោយការបំភ្លឺនៃការប្រើប្រាស់មធ្យោបាយសេដ្ឋកិច្ចដែលមានការត្រលប់មកវិញនៃអត្រាសេដ្ឋកិច្ចខាងក្នុង (EIRR) ដូចបង្ហាញខាងក្រោម :

1- USP (3.500 ហ.ត) មានការត្រលប់មកវិញនៃអត្រាសេដ្ឋកិច្ចខាងក្នុង (EIRR) 10 % និងមធ្យោបាយសេដ្ឋកិច្ចដែលមានគ្រប់គ្រាន់ ។ វាគឺជាសេចក្តីសង្ឃឹមដ៏ខ្ពស់ដើម្បីនឹងបង្កើនឱ្យបានគ្រប់គ្រាន់ នូវប្រាក់ចំណូលពីកសិកម្មសំរាប់ការទូទាត់តំលៃប្រតិបត្តិការ និង ការជួសជុលថែទាំនូវសំណង់ទាំងអស់របស់គំរោង ។

2- ក្នុងចំណោមអាងទឹកតូចៗចំនួន 15 អាងទឹកកំសីនៃ SRP (21 ហ.ត) និងអាង 160 នៃ SRP (21 ហ.ត) មាន EIRR ខ្ពស់គឺ 9,4% និង 9,8 % ។

3- PDP មានមធ្យោបាយសេដ្ឋកិច្ចខ្ពស់ជាងគេក្នុងឱកាសនៃ EIRR ប៉ុន្តែភាពសំខាន់នៃការប៉ះពាល់សេដ្ឋកិច្ចកសិកម្ម នៅក្នុងខណៈពេលដែលកំណើនប្រាក់ចំណូលសុទ្ធដែលបានប្រៀបធៀបតិចជាងតំបន់ទាំងពីរគឺ USP និង SRP ។

56. **ការជ្រើសរើសគំរោងអាទិភាពទាំងឡាយសំរាប់ការសិក្សាដំបូង :**

ផែនការអភិវឌ្ឍន៍ការស្រោចស្រពជាបន្តបន្ទាប់ (USP SRP និង PDP) បានត្រូវជ្រើសរើសជាគំរោងអាទិភាពសំរាប់ការសិក្សាដំបូង :

1-ផែនការសាងសង់ឡើងវិញនូវការស្រោចស្រពនៅតំបន់ផ្នែកខាងលើស្ទឹងស្លាគូ (USP) ប្រមាណ3.500 ហ.ត

2- ផែនការស្តារជួសជុលឡើងវិញ អាងទឹកតូចៗ (SRP) ប្រមាណ 42 ហ.ត ដែល :

- កំសី (21 ហ.ត)
- អាង 160 (21 ហ.ត)

3- ផែនការអភិវឌ្ឍន៍ស្រះទឹកតូចៗ (PDP) :

ការងារទាំងនេះវាមានបីប្រភេទនៅក្នុងផែនការ :

1- ស្រះទឹកដែលប្រើប្រាស់ជាឯកជន

2- ស្រះទឹកដែលប្រើប្រាស់ដោយក្រុមកសិករ

3- ស្រះទឹកក្នុងប្រលាយដែលប្រើប្រាស់ដោយក្រុមកសិករ

ដើម្បីនឹងបង្កើតឡើងនូវផែនការអភិវឌ្ឍន៍ស្រះតូចៗនៅក្នុងករិតដំបូង យ៉ាងហោចណាស់ក៏ផែនការអភិវឌ្ឍន៍មួយ សំរាប់ប្រភេទស្រះទឹកនីមួយៗគំរូឱ្យសិក្សាជា PDP គំរូនៅក្នុងភូមិមួយ ។ ស្រះក្នុងប្រឡាយមាន EIRR ខ្ពស់ជាងប្រភេទដទៃទៀត និងសក្តានុពលទឹកដែលមាននៅក្នុងប្រលាយស្រាប់ គឺជាកត្តាមធ្យោបាយមួយ ។ ស្ថិតនៅក្នុងការពិចារណានៃលក្ខខ័ណ្ឌយ៉ាងដូច្នេះ ភូមិមួយនៅក្នុងឃុំញ៉ែងញ៉ង គ្របដណ្តប់ទៅដោយប្រឡាយចំនួន 8 បានត្រូវជ្រើសរើសសំរាប់ការសិក្សាដំបូង ។

សំរាប់កម្មវិធីពង្រីកផ្លូវជនបទ (RIP) ផ្លូវអាទិភាពចំនួនបីជាបន្តបន្ទាប់មានប្រវែងសរុប 24,5 គម បានត្រូវជ្រើសរើសសំរាប់ការសិក្សាដំបូង :

1- ពីត្រពាំងធំខាងជើងទៅត្រពាំងក្រញូង (13 គម)

2- ពីអូរសារ៉ាយ ទៅ ផ្លូវស្ទឹងស្លាគូ (5.5 គម)

3- ផ្លូវខ្ពបស្វាយ (6 គម)

កម្មវិធីគាំទ្រដទៃទៀត សំរាប់ការជ្រើសរើសគំរោងស្រោចស្រពអាទិភាព ក៏ត្រូវតែសិក្សានៅក្នុងករិតដំបូង ដើម្បីនឹងធ្វើឱ្យប្រាកដនូវការប៉ះពាល់ដល់ការអភិវឌ្ឍន៍ការស្រោចស្រព និងឥទ្ធិពលសង្គមដទៃទៀត និងសេចក្តីបញ្ជាក់ការលើកកំពស់នៃស្តង់ដាររស់នៅរបស់កសិករ ។

1-កម្មវិធីផលិតផលកសិកម្ម

2- កម្មវិធីគាំទ្រដល់វិស័យកសិកម្ម

3- កម្មវិធីអភិវឌ្ឍន៍ស្ថាប័ន

4- កម្មវិធីអភិរក្សបរិស្ថាន

57. **សិក្ខាសាលាស្តីពីការចូលរួមនៅជនបទ** (PRA):

សិក្ខាសាលាចំនួន 20 លើកបានប្រព្រឹត្តទៅក្នុងរយៈពេល បួនថ្ងៃ គឺពីថ្ងៃ 13 ខែមិថុនា ទៅដល់ថ្ងៃ 16 ខែមិថុនា ឆ្នាំ 2001 ដែល 12 លើកជាមួយអ្នកទទួលផល 6 លើកជាមួយបុគ្គលិករដ្ឋបាលក្នុងតំបន់ 1 លើកជាមួយ NGOs និង1លើកទៀតជាមួយអង្គការរដ្ឋាភិបាលក្នុងតំបន់ ។ សរុបអ្នកចូលរួមនៅក្នុងសិក្ខាសាលាទាំងនេះមានច្រើនជាង 280 នាក់ ដែលចំនួនអ្នកចូលរួមសំរាប់សិក្ខាសាលានីមួយៗ មានស្រីប្រមាណ 40% ហើយជាលទ្ធផលពង្រាងបួង់មេបានត្រូវទទួលយកដោយអ្នកចូលរួមទាំងអស់ក្នុងសិក្ខាសាលានេះ ។

# ជំពូកទី III
# ជំរើសការសិក្សាលើផ្ទៃដីស្រោចស្រពនៃគំរោងស្លាគូផ្នែកខាងលើ

58. គំរោងស្លាគូផ្នែកខាងលើ (USP) ដែលបានជ្រើសរើសជាអាទិភាពក្នុងខណៈកំពុងសិក្សាគំរូប្លង់មេ (Master Plan) បំណងស្រោចស្រពផ្ទៃដី 3,500 ហិចតា ដោយការស្តាបនាឡើងវិញនូវអាងទឹកពីរមានទីតាំងលើស្ទឹងស្លាគូ ហើយវាបានហូរទៅកាន់ប្រឡាយបង្វែរទឹករវាងអាងទឹកពីរ ។ ប្រឡាយមេពីរខ្សែ (ប្រឡាយលេខ 33 និងប្រឡាយកោះក្អែក) និងប្រឡាយលេខ 24 ដែលចំនុចចាប់ផ្តើមពីអាងទឹកខ្ពបត្របែក និងប្រឡាយរងរបស់វា ។ នៅក្នុងដំណាក់កាលដំបូងនៃការសិក្សានូវអ្វីៗដែលអាចធ្វើទៅបាន (សំណង់ទំនប់ ប្រឡាយ ផ្ទៃដីស្រោចស្រព...) វគ្គ – II ការងារវាស់ស្ទង់លំអិតយ៉ាងច្រើន ដែលបានប្រព្រឹត្តទៅតាមបណ្តោយប្រឡាយមេកោះក្អែក ។ ក្នុងការបន្ថែមផែនទីឋានលេខា 1/10.000 ជាមួយខ្សែវ៉ណ្ណ 1 ម ចន្លោះពេលដែលបានរៀបចំជាថ្មីសំរាប់តំបន់អាទិភាពនៃគំរោងស្លាគូផ្នែកខាងលើ (USP) ។ លើមូលដ្ឋានទិន្នន័យជាច្រើនដែលបានពិភាក្សាថ្មីៗថាប្រឡាយមេកោះក្អែក ដែលមានស្រាប់មិនមានលក្ខណៈគ្រប់គ្រាន់នឹងបានស្តាបនាឡើងវិញទេ ហើយវាមិនមានមុខងារត្រឹមត្រូវដូចប្រឡាយបន្ទាប់ពីការស្តាបនាឡើងវិញ ។ កំរិតកំពស់បាតប្រឡាយដែលមានស្រាប់ឡើងចុះៗ (ផ្លាស់ប្តូរជានិច្ច) តាមបណ្តោយមុខកាត់ប្រឡាយដែលតំរូវឱ្យជីកជំរៅពី 6 ម ទៅ 7 ម ដែលជាជំរៅជីកអតិបរមាសំរាប់ការស្តាបនាប្រឡាយ ។ សូមមើល **Figure III – 1.1** ។ លើសពីនេះទៀតក្នុងការស្តាបនាបរិមាណដីជីក ការថែទាំជើងទេរ និង តំរូវការសំណង់ដោះទឹកសំរាប់ការពង្រីងប្រឡាយដ៏សំខាន់ ហើយតំលៃនៃការថែទាំ និងការស្តាបនាឱ្យល្អ ហើយជាបន្ទាន់ផងដែរ ។ ដូចនេះការស្តារឡើងវិញនៃប្រឡាយមេកោះក្អែក ដែលមានស្រាប់មិនត្រូវបានពិចារណាដូចដែរ "ផែនការគំរូសមរម្យនៃការស្តារ និង

ស្ថាបនាឡើងវិញ" ។

59. ជំនួសប្រឡាយមេកោះក្អែកដែលមានស្រាប់ ហើយជំរើសជាបន្តបន្ទាប់ដែលបានប្រៀបធៀបជាចំបង លើតំលៃនៃការស្ថាបនា ។

**ជំរើសទី 1**: ប្រឡាយកោះក្អែកថ្មី (1.600 ហ.ត : 11.5 គ.ម) + ប្រឡាយ 33 (1,900 ហ.ត : 7.3 គ.ម) + ប្រឡាយរង (36.5 គ.ម) + ប្រព័ន្ធស្រោចស្រព (មើល **Figure III-2.1.**)

**ជំរើសទី 2**: ប្រឡាយ 33 (3.500 ហ.ត : 7.3 គ.ម) + ប្រឡាយរង (44.7 គ.ម) + ប្រព័ន្ធស្រោចស្រព (មើល **Figure III-2.2.**)

**តំលៃស្ថាបនានៃផែនការដែលបានជ្រើសរើស**

ឯកតា : US$ 1000

| ប្រភេទ | ជំរើសទី 1 | ជំរើសទី 2 |
|---|---|---|
| ប្រឡាយមេ 33 | 675 | |
| ប្រឡាយមេកោះក្អែកថ្មី | | - |
| សរុបរង | | 707 |
| ប្រឡាយរង និង ប្រឡាយស្រោចស្រព | | 4.781 |
| សរុប | | 5.578 |
| តំលៃក្នុង 1 ហិចតា | | 1.6 |

មានភាពខុសគ្នាយ៉ាងច្រើនរវាងតំលៃស្ថាបនានៃជំរើសទាំងពីរ ។ ជំរើសទី 2 ត្រូវបានសំរេចចុងក្រោយក្នុងការជ្រើសរើសផ្ទៃដីស្រោចស្រពនៃគំរោងស្លាគូផ្នែកខាងលើ (USP) ។ ផ្ទៃដី 3.500 ហិចតា មិនត្រូវបានផ្លាស់ប្តូរចំនួន ប៉ុន្តែទីតាំងនៃផ្ទៃដីស្រោចស្រព ត្រូវបានផ្លាស់ប្តូរដូចបង្ហាញក្នុង **Figure II-2.2.** ។

# ជំពូកទី IV ការសិក្សានូវអ្វីៗដែលអាចធ្វើបានសំរាប់គំរោងអាទិភាព

## IV-2 ផែនការស្ថាបនាឡើងវិញប្រព័ន្ធស្រោចស្រពស្ទឹងស្លាគូផ្នែកខាងលើ (USP)

60. ការសិក្សាឡើងវិញដែលអាចធ្វើទៅបានលើ (USP) បានប្រព្រឹត្តទៅតាមផែនការស្ថាបនាឡើងវិញ ដែលបានស្នើរឡើង (មើល **Figure IV-1.4.1**) :

- ផ្ទៃដីស្រោចស្រពសុទ្ធ : 3.500 ហ.ត
- អ្នកចូលរួមទទួលផលប្រយោជន៍ : 4.020 គ្រួសារ 32 ភូមិ និង 5 ឃុំ ក្នុងស្រុកត្រាំកក់ ។
- ស្ថាបនាឡើងវិញនៃអាងទឹកទំនប់លោក រួមជាមួយសំណង់បង្ហៀរ (មើល **Figure IV-2.3.1.**) (ផ្ទៃរងទឹកភ្លៀង = 332 គម$^2$ បរិមាណទឹករក្សាជាក់លាក់ = 1 លានម៉ែត្រគូប កំរិតកំពស់ខ្នងទំនប់

EL=43.3 ម ធារទឹកជំនន់ (100 ឆ្នាំ) = 420 ម³/វិនាទី កំរិតកំពស់ទឹកអតិបរមា EL=41.3 ម អប្បបរមា EL=40.4 ម និងប្រវែងទំនប់ L= 2.5 គ.ម)

- ស្តាបនាឡើងវិញនៃអាងទឹកខ្លបត្របែក រួមជាមួយសំណង់បង្ហូរទឹកចូល និង សំណង់បង្ហៀរ (មើល **Figure IV-2.3.2.**) (ផ្ទៃរងទឹកភ្លៀង = 137 គម² បរិមាណទឹករក្សាជាក់លាក់ = 2.63 លានម៉ែត្រគូប កំរិតកំពស់ខ្នងទំនប់ EL=39.0 ម ធារទឹកជំនន់ (100 ឆ្នាំ) = 195 ម³/វិនាទី កំរិតកំពស់ទឹកអតិបរមា EL=37.3 ម អប្បបរមា EL=34.2 ម ប្រវែងទំនប់ L=3.3 គ.ម)
- ស្តាបនាឡើងវិញនៃប្រឡាយបង្វែរទឹក (Q=3.5 ម³/វិនាទី L=9.4 គ.ម) រវាងអាងទឹកទាំងពីរខាងលើ ។
- ស្តាបនាឡើងវិញនូវប្រឡាយមេ 33 (Q=3.2 ម³/វិនាទី L=7.3 គ.ម)
- ស្តាបនាឡើងវិញនូវប្រឡាយ 24 (Q=0.6 ម³/វិនាទី L=5.7 គ.ម)
- ស្តាបនាឡើងវិញនូវប្រឡាយរង 6 ខ្សែផ្សេងទៀតមានប្រវែងសរុប (L=39 គ.ម)
- ការអភិវឌ្ឍទឹកសិដ្ឋានរួមជាមួយប្រឡាយស្រោចស្រព (1/ 33 ហិចតាជាមធ្យម) និងផ្លូវទឹក (1 / 5 ហិចតាជាមធ្យម) មើល **Figure IV-2.3.3** ។

## IV-3 ផែនការស្តាបនាឡើងវិញអាងទឹកខ្នាតតូច (SRP)

61. ផែនការស្តាបនាឡើងវិញអាងទឹកខ្នាតតូច (SRP) មានពីរគំរោងឈ្មោះថាអាងទឹក 160 SRP និងអាងទឹក កំសី SRP ។ ការសិក្សានូវអ្វីៗដែលអាចធ្វើទៅបានលើគំរោងទាំងពីរនេះ ប្រព្រឹត្តទៅបានតាមផែនការស្តារឡើងវិញជាបន្តបន្ទាប់ដែលស្នើឡើង :

**(1) អាងទឹក 160 SRP** (មើល **Figure IV-3.2.1.**)

- ផ្ទៃដីស្រោចស្រពសុទ្ធ : 25 ហិចតា
- អ្នកចូលរួមទទួលផលប្រយោជន៍ :130 គ្រួសារក្នុងភូមិត្រពាំងឈូក
- ការស្តារឡើងវិញនៃអាងទឹករួមជាមួយសំណង់បង្ហូរទឹកចូល និងសំណង់បង្ហៀរ (ផ្ទៃរងទឹកភ្លៀង = 2 គម² បរិមាណទឹករក្សាជាក់លាក់ = 29.300 ម³ កំរិតកំពស់ខ្នងទំនប់ EL=46.5 ម ធារទឹកជំនន់ (20ឆ្នាំ) = 6 ម³/វិនាទី កំរិតកំពស់ទឹកអតិបរមា EL=45.3 ម អប្បបរមា EL=44.0 ម) ។

**(2) អាងទឹកកំសី SRP** (មើល **Figure IV-3.2.2.**)

- ផ្ទៃដីស្រោចស្រពសុទ្ធ : 27 ហិចតា
- អ្នកចូលរួមទទួលផលប្រយោជន៍ : 37 គ្រួសារក្នុងភូមិកំសី
- ស្តារឡើងវិញនៃអាងទឹក រួមជាមួយសំណង់បង្ហូរទឹកចូល និងសំណង់បង្ហៀរ (ផ្ទៃរងទឹកភ្លៀង = 5.2 គម² បរិមាណទឹករក្សាជាក់លាក់ = 19.700 ម³ កំរិតកំពស់ខ្នងទំនប់

EL=13.8 ម ធារទឹកជំនន់ (20ឆ្នាំ) =11.4 ម$^3$/វិនាទី កំរិតកំពស់ទឹកអតិបរមា EL=12.6 ម អប្បបរមា EL=12.0 ម) ។

## IV-4 ផែនការអភិវឌ្ឍន៍ស្រះទឹកតូចៗ (PDP)

62. PDP រួមមានស្រះ 3 ប្រភេទ ឈ្មោះថា i) ស្រះជាក្រុម ii) ស្រះឯកត្តជន និង iii) ស្រះទឹកប្រើប្រឡាយដែលមានស្រាប់ ។ ដូចក្នុងគំរោងគំរូនៃ PDP ភូមិត្រពាំងស្មោរត្រូវបានជ្រើសរើសក្នុងឃុំញ៉ែងញ៉ង ហើយការសិក្សានូវអ្វីៗដែលអាចធ្វើទៅបានលើគំរោងគំរូ ដែលបានប្រព្រឹត្តទៅនឹងបានស្នើរជាបន្តបន្ទាប់នៃ PDP ក្នុងភូមិត្រពាំងស្មោរ :

- ផ្ទៃដីស្រោចស្រពសុទ្ធ : សរុប 5.8 ហិចតា
- អ្នកចូលរួមទទួលផលប្រយោជន៍ : សំរាប់ 88 គ្រួសារ ក្នុងភូមិត្រពាំងស្មោរ
- ចំនួនស្រះ : 30 ស្រះ ប្រកបឡើង 14 ស្រះជាក្រុម 13 ស្រះឯកត្តជន និង 3 ស្រះទឹកប្រើប្រឡាយដែលមានស្រាប់ (មើល **Figure IV-4.1.2.**) ។

ផែនការខាងលើគ្របដណ្តប់ប្រហែល 80 % នៃគ្រួសារសរុប និង 70 % នៃប្រជាជនសរុបក្នុងភូមិ ។

## IV-5 កម្មវិធីទ្រទ្រង់

63. **កម្មវិធីផលិតកម្មកសិកម្ម (សូមមើល Figure IV-5.1.1.)**

**(1) USP** : ស្រូវរដូវវស្សាចំនួន 3.500 ហ.ត នឹងត្រូវស្រោចស្រព ហើយទឹកនេះនឹងស្រោចស្រពបន្ថែមលើផ្ទៃ ដី 500 ហ.ត និងដំណាំរួមផ្សំចំនួន 550 ហ.ត មុន និងក្រោយការដាំដុះស្រូវតែរៀងៗខ្លួន ។ ចំពោះដំណាំរួមផ្សំ (ពោត សណ្តែកដី សណ្តែកសៀង សណ្តែកខៀវ ល្ង និងបន្លែជាច្រើនប្រភេទទៀត) នឹងបង្កើនប្រាក់ចំណូលគ្រួសារកសិករ ។ ទោះបីជាយ៉ាងណាក៏ដោយ ចាំបាច់ណាស់ត្រូវជួយទ្រទ្រង់ដល់ពួកគាត់នៅទីផ្សារលក់ផលិតផលផងដែរ ។

**(2) អាង 160 SRP** : គំរូដាំដុះមានលក្ខណៈស្រដៀងគ្នានឹង USP ដែលនឹងត្រូវអនុវត្តន៍នៅអាង 160 SRP ដោយពិចារណាលើលទ្ធភាពទឹកស្រោចស្រព អាងទឹកដែលបានស្តារឡើងវិញនឹងស្រោចស្រពលើស្រូវនៅរដូវវស្សាចំនួន 25 ហ.ត ដែល 17 ហ.ត ស្រូវក្នុងស្រុក និង 8 ហ.ត ស្រូវបង្កាត់ ។ បន្ថែមពីនេះដំណាំរួមផ្សំ នឹងត្រូវស្រោចស្រពលើផ្ទៃដី 2 ហ.ត និង 3 ហ.ត មុន និងក្រោយការដាំដុះស្រូវនីមួយៗ ។

**(3) កំសី SRP** : កំសី SRP ត្រូវតែគំណត់ប្រភពទឹកដោយអាស្រ័យលើទំហំអាងទឹក ។ ការដាំដុះតែមួយគត់នឹងអាចស្រោចស្រពបាននូវរដូវវស្សា ។ គំរោងបានស្នើឡើងថាដំណាំរួមផ្សំចំនួន 3 ហ.ត នឹងត្រូវដាំក្រោយពេលធ្វើថ្នាលរួច 16 ហ.ត ស្រូវក្នុងស្រុក និង 8 ហ.ត ស្រូវពូជបង្កាត់ ។ ការស្រោចស្រពពេលរៀបចំថ្នាលរួចនឹងធ្វើឱ្យប្រសើរឡើងនៅផលិតកម្ម និងទិន្នផលស្រូវដែលរំពឹងលើទឹកភ្លៀង ។

(4) **ត្រពាំងស្ពោរ PDP** : ពិចារណាពីប្រភពទឹកដែលមានកំរិតកំណត់ ការស្រោចស្រពបានស្នើឡើងសំរាប់ការធ្វើផ្កាលស្រូវចំនួន 1 ហ.ត ដំណាំរួមផ្សំចំនួន 4.82 ហ.ត ក្នុងរដូវវស្សា និងដំណាំរួមផ្សំចំនួន 2.64 ហ.ត ក្នុងរដូវប្រាំង ។

64. ទិន្នផលស្រូវគោលដៅ និងដំណាំរួមផ្សំ បានប៉ាន់ស្មានតាមរយៈការត្រួតពិនិត្យទិន្នផលផ្ទៃដីស្រោចស្រពដែលមានស្រាប់ក្នុង និងជុំវិញតំបន់គំរោង ។ ផលិតកម្មស្រូវនឹងទទួលបានចំនួន 10.350 តោននៅតំបន់ USP ចំនួន 74 តោននៅតំបន់អាង 160 SRP និងចំនួន 71 តោននៅកំសី SRP ។ ផលិតកម្មនឹងកើនថែមទៀតចំនួន 6.050 តោន 37 តោន និង 37 តោន នៅគំរោងដែលរំពឹងទុក ។ ជាពិសេសដំណាំរួមផ្សំនៅតំបន់ USP នឹង ក្លាយជាដំណាំចំបងសំរាប់ប្រភពប្រាក់ចំណូលរបស់អ្នកទទួលផលប្រយោជន៍ ។ ចំពោះដំណាំរួមផ្សំនៅ PDP នឹងចូលរួមបង្កើនប្រាក់ចំណូលដល់អ្នកទទួលផលប្រយោជន៍ផងដែរ ។

65. តុល្យភាពស្បៀងក្នុងតំបន់ USP និង SRP នឹងត្រូវធ្វើឱ្យប្រសើរឡើងតាមរយៈការបង្កើនផលិតកម្មស្បៀង ។ ស្រូវសល់ពីតំរូវការរបស់គំរោងនីមួយៗនឹងមានចំនួន 4.200 តោន នៅក្នុងតំបន់ USP ចំនួន 20 តោន នៅក្នុងអាង 160 SRP និងចំនួន 47 តោន នៅក្នុងកំសី SRP ។ ស្រូវសល់ពីតំរូវការជាមធ្យមក្នុងគ្រួសារនឹងមាន ចំនួន 1.050 គ.ក នៅ USP ចំនួន 150 គ.ក នៅអាង 160 SRP ហើយនិងចំនួន 1.280 គ.ក នៅកំសី SRP ។ ផលិតកម្មស្រូវនៅ PDP អាចកើនឡើងដោយសារផ្ទៃដីធ្វើស្រែថយចុះ ប៉ុន្តែអ្នកទទួលផលប្រយោជន៍នឹងទទួលបានចំណូលជាសាច់ប្រាក់ច្រើនពីដំណាំរួមផ្សំ ។ ស្រូវសល់ពីតំរូវការអាចលក់នៅទីផ្សារនឹងចូលរួមកែលំអតុល្យភាពស្បៀងនៅស្រុកត្រាំកក់ និងភូមិជិតៗគ្នាទៅនឹងតំបន់គំរោង ។ ប្រហែល 10 % ទៅ 20 % នៃបន្លែដែលបានដាំនៅតំបន់ USP នឹងទុកប្រើប្រាស់នៅផ្ទះ និងលក់នៅទីផ្សារមូលដ្ឋានទៀតផង ។ បរិមាណដែលនៅសល់ 80 – 90 % នឹងអាចលក់នៅទីផ្សារដែលជាតំបន់ពេញនិយមដូចជានៅភ្នំពេញ និង ទីក្រុងតាកែវជាដើម ។ កម្មវិធីជួយទ្រទ្រង់ចំពោះទីផ្សារបន្លែមានសារៈប្រយោជន៍ណាស់ ។

66. **កម្មវិធីផ្សព្វផ្សាយកសិកម្ម**

ផែនការផ្សព្វផ្សាយកសិកម្មបានស្នើឡើងមាន 3 បែបគឺ i) ផែនការពង្រឹងសេវាផ្សព្វផ្សាយកសិកម្ម ii) ផែនការផលិតពូជស្រូវ និង iii) ផែនការចែកចាយធនធានកសិកម្ម ។

(1) **ផែនការពង្រឹងសេវាផ្សព្វផ្សាយកសិកម្ម** : ការផ្សព្វផ្សាយបានធ្វើឱ្យប្រសើរដល់ការអនុវត្តន៍ការដាំដុះ និងការស្រោចស្រពការដាំដុះនឹងត្រូវធ្វើឡើងដោយសកម្មភាពសេវាផ្សព្វផ្សាយរបស់មន្ទីរកសិកម្មខេត្តតាកែវ តាមរយៈ VDC និង FWUC ។ ផែនការផ្សព្វផ្សាយ គឺជាមូលដ្ឋានដូចគ្នា និងគំរោងបច្ចុប្បន្នរបស់ប្រព័ន្ធផ្សព្វផ្សាយ DAFF ដែរប្រព័ន្ធបច្ចុប្បន្ន គឺបានស្នើឱ្យមានការពង្រឹងថែមទៀត ជាពិសេសទៅលើសកម្មភាពការងារនៅក្នុងស្រែរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ (VEWs) ។ ក្នុងគោលបំណងនេះដែរការងារនេះ ត្រូវបានស្នើឡើងជាកម្មវិធីទ្រទ្រង់កសិកម្មដែលការផ្សព្វផ្សាយ FGs រួមមាន VEWs គួរតែបានរៀបចំក្រោម VDC និងស្រែបង្ហាញគួរតែបានបង្កើតឡើងក្នុងស្រែកសិករ ។

(2) **ផែនការផលិតពូជស្រូវ** : ការចែកចាយពូជស្រូវបានបន្សុតរួចទាំងពីរ ពូជក្នុងស្រុក និង ពូជបង្កាត់

(HYVs) ដែលខានមិនបានសំរាប់បង្កើនផលិតកម្ម និងធ្វើឱ្យប្រសើរនូវគុណភាពស្រូវ ។ ការងារនេះបានស្នើឡើងចំពោះពហុពូជស្រូវដោយផលិតពូជរបស់ FG នៅក្នុងតំបន់អត្ថិភាព ។ តំរូវពូជស្រូវនឹងត្រូវដាំនៅដីស្រែពី 25 ទៅ 30 ហ.ត ឬប្រហែលជា 30 គ្រួសារ ។ ពូជដែលបានផលិតរួចនឹងត្រូវត្រួតពិនិត្យដោយ DAFF ។ ពូជបានចេញវិញ្ញាប័នប័ត្របន្ទាប់ពីការត្រួតពិនិត្យនឹងត្រូវបានចែកទៅឱ្យកសិករ តាមរយៈការផ្សព្វផ្សាយ FGs ។

**(3) ផែនការចែកចាយធាតុចូលកសិកម្ម** : ដោយផ្អែកលើគោលនយោបាយសេដ្ឋកិច្ចទីផ្សារសេរី ធាតុចូលកសិកម្មដូចជា ជី និងពូជដំណាំរួមផ្សំនឹងត្រូវបានផ្គត់ផ្គង់នៅទីផ្សារដោយអ្នកលក់ ។ ដោយសារទ្រង់ទ្រាយការដាំដុះតិចតួចរបស់អ្នកទទួលផលប្រយោជន៍ តំរូវការធាតុចូលក្នុងមួយគ្រួសារ គឺមានតិចតួចបំផុត ។ ចំណាយដឹកជញ្ជូនខ្ពស់ពីទីផ្សារ (ផ្សារអង្គរកា ឬ ផ្សារអង្គតាសោម) ទៅភូមិ ។ ថ្លៃជីនៅកសិដ្ឋានជាទូទៅថ្លៃ 5-7 % ខ្ពស់ជាងនៅផ្សារតាកែវ និងផ្សារអង្គតាសោម ។ ដូច្នេះវាបានផ្ដល់អនុសាសន៍ថាការផ្សព្វផ្សាយ FGs ទទួលរ៉ាប់រងក្រុមទិញធាតុចូល រួមមានពូជស្រូវបានផលិតដោយក្រុមកសិករផលិតពូជ ។ កសិករអាចទទួលធាតុចូលថ្លៃទាបជាង និងគុណភាពខ្ពស់ជាងតាមរយៈការទិញជាក្រុម ។ ទង្វើរនេះក៏បានផ្ដល់អនុសាសន៍ផងដែរ ដែលការផ្សព្វផ្សាយ FGs យកថ្លៃចំណាយផ្សេងៗពីរ ឬ បីភាគរយពីកសិករជាប្រាក់សំរាប់សកម្មភាពផ្សព្វផ្សាយ FGs ដូចជាការងារ VEWs និងស្រែបង្ហាញ ។

67. **សេវាឥណទាន**

នៅពេលកសិករទិញជី និងពូជក្នុងផែនការ USP បានស្នើឡើងចំណាយនេះបានប៉ាន់ស្មានចំនួនសរុប 180លានរៀល ដែលស្មើតំលៃប្រហែល 3.4 ដង នៃចំនួនសរុប 240លានរៀល នាពេលបច្ចុប្បន្ននេះ ។ ចំណាយជាមធ្យមក្នុងមួយគ្រួសារនឹងកើនពី 60.000រៀល ពេលបច្ចុប្បន្នទៅ 200.000រៀល ជាសរុបដែលមានស្រូវ (135.000រៀល) និងដំណាំរួមផ្សំ (65.000រៀល) ។ កសិករនឹងត្រូវការឥណទាន សាច់ប្រាក់ដើម្បីទិញធាតុចូល ។ ប្រព័ន្ធឥណទាន 3 យ៉ាងខាងក្រោមនេះនឹងអាចឱ្យកសិករទិញធាតុចូលបានដូចជា :

**(1) ឥណទានជី FGs ស្ថិតនៅក្រោម VDC** : សេវាឥណទានជីពី FGs ស្ថិតនៅក្រោម VDC គឺបានដំណើរការក្នុង 30 ភូមិ និងនៅសល់ 5 ភូមិទៀតសេវាឥណទានដូចគ្នានេះនឹងចាប់ផ្ដើមនៅក្នុងឆ្នាំ 2002 ខាងមុខនេះ ។

**(2) ឥណទានពី NGOs** : ធនាគារពាណិជ្ជមួយ និង NGOs ក្នុងស្រុកជាច្រើនទៀតធ្វើការខាងសេវាឥណទានខ្នាតតូចក្នុងតំបន់អត្ថិភាព ។ អត្រាការប្រាក់ជាទូទៅគឺ 4% ក្នុងមួយខែ ។

**(3) ឥណទានពីប្រភពធនបំរុងរបស់ FWUC** : FWUC នឹងរក្សាទុនទុនបំរុង សំរាប់ជិនួសឱ្យសំណង់ស្រោចស្រពដែលបានទុនមកពីការប្រមូលថ្លៃប្រើប្រាស់ទឹក (ISF) ។ ទុននោះនឹងកើនឡើង ។ គេបានស្នើឡើងថាទុនបំរុងជាផ្នែកមួយដែលបានប្រើសំរាប់សេវាឥណទានតែមួយគត់ ដើម្បីបន្ថយការទិញធាតុចូលក្នុងតំបន់ដែលមានការយល់ព្រមពី FWUC ។ ទុននេះនឹងរៀបចំស្ថិតនៅក្រោម FWUC ។ អត្រាការប្រាក់បានស្នើឡើងមានចំនួន 2% ក្នុងមួយខែដូចគ្នាទៅនិងសេវាឥណទាន VDC ដែរ ។

68. **កម្មវិធីជំនួយទីផ្សារ**

ក្រោយពេលសហគមន៍កសិករប្រើប្រាស់ទឹក (FWUC) នៅ USP បានរៀបចំ ហើយស្រូវនឹងត្រូវគេប្រមូលជាថ្លៃប្រើប្រាស់ទឹក (ISF) ពីកសិករជាសមាជិក ។ ទោះបីជាយ៉ាងណាក៏ដោយគ្មានអគារសមស្រប សំរាប់ការប្រមូលស្រូវ ការសំអាត និងការទុកដាក់មុនពេលលក់ទៅអ្នកទិញទេ ។ តំបន់ USP នឹងដាំដំណាំរួមផ្សំដូចជា ពោត សណ្តែក សណ្តែកដី បន្លែ ទាំងក្នុងរដូវវស្សា (500 ហ.ត) និងរដូវប្រាំង (550 ហ.ត) ដែលមានបរិមាណច្រើនចំពោះកសិករធ្វើជំនួញផ្ទាល់ខ្លួននៅក្នុងតំបន់ ។ ជាងនេះទៅទៀតគ្មានទីផ្សារដែលប្រមូលផ្តុំផលិតផលបរិមាណច្រើននៅជិតតំបន់គំរោងទេ ។ នៅពេលកម្មវិធីជួយគាំទ្រមួយសំរាប់គំរោងស្រោចស្រពអត្ថិភាពបានស្នើឡើង ជាពិសេសចំពោះតំបន់ USP ដោយសារតែទំហំផលិតផលនៅពេលអនាគតតែប៉ុណ្ណោះ សេវាជំនួយទីផ្សារនឹងមានសារៈប្រយោជន៍ចំពោះនិរន្តរភាពគំរោងមានដូចតទៅ :

- ការទុកដាក់ និង ការលក់ស្រូវដែលបានប្រមូលពី ISF
- ការប្រមូលផ្តុំ និងជំនួយទីផ្សារ

69. (1) **ការទុកដាក់ និង ការលក់ស្រូវដែលបានប្រមូលពី ISF :**

ស្រូវដែលប្រមូលពី ISF នឹងត្រូវទុកដាក់នៅ 6 ឃ្លាំង និងបានលក់នៅទីផ្សារ នៅពេលស្រូវថ្លៃបំផុតនៅទីផ្សារ ។ ក្រៅពីការទុកដាក់ និងការលក់ ជាងនេះទៅទៀតចំណូលប្រហែល 15.68 លានរៀលនឹងកើនថែមទៀតពីថ្លៃលក់របស់របរផ្សេងទៀត ។

(2) **ការប្រមូលផ្តុំ និង ជំនួយទីផ្សារ :**

ការប្រមូលផ្តុំ និងជំនួយទីផ្សារមានគោលបំណង :

- ផ្តល់កន្លែងរកស៊ីជាសាធារណៈមួយចំពោះកសិករសមាជិក FWUC
- ផ្តល់ឱកាសឱ្យសមាជិកទាំងនោះចរចារតំលៃជាមួយអ្នកទិញ
- ផ្សព្វផ្សាយដល់សមាជិកទាំងឡាយពីថ្លៃនៅទីផ្សារ បានកំណត់តាមគុណភាព និង បរិមាណ
- ទទួលពត៌មានពីទីផ្សារ និងតំលៃនៅទីផ្សារធំៗ
- ផ្តល់ឱកាសដោយបង្កើនប្រាក់ចំណូលសមាជិកតាមរយៈជំនួយទីផ្សារ

ការប្រមូលផ្តុំ និងជំនួយទីផ្សារមាន i) ជំនួយការលក់ដុំដោយប្រើអគារផ្សារប្រមូលផ្តុំ និង ii) ចូលរួមជំនួយដឹកជញ្ជូននឹងត្រូវអនុវត្តន៍នៅ 5 ឆ្នាំក្រោយ ។ ចំណូលដុលកើនថែមពីការប្រមូលផ្តុំ និងជំនួយទីផ្សារតាមក្រុមទីផ្សាររបស់គណៈកម្មាការកំពូលនៃ FWUC បានប៉ាន់ស្មាន 54 លានរៀលពីជំនួយការលក់ដុំ និង 128 លានរៀល ពីការចូលរួមជំនួយដឹកជញ្ជូន ។ បរិមាណលក់ចំពោះជំនួយការលក់ដុំគឺ 40 % នៃចំនួនអាចលក់ចេញលើសពីតំរូវការរបស់ផលិតកម្មក្នុងតំបន់ដាំដុះ USP ខណៈដែលការចូលរួមជំនួយដឹកជញ្ជូនគឺ 10 % នៃចំនួនអាចលក់ចេញលើសពីតំរូវការរបស់ផលិតកម្មដាំដុះក្នុងតំបន់ USP ។

70. **កម្មវិធីពង្រីកផ្លូវជនបទ (RIP)**

លទ្ធភាពនៃការសិក្សាតំបូងនៅលើកំណាត់ផ្លូវដែលមានជាបន្តបន្ទាប់ :

1) ផ្លូវលេខ 33 (ត្រពាំងធំខាងជើង ~ ត្រពាំងក្រញូង (ផ្លូវ-A)

2) ចេញពីអូសាវ៉ាយ ~ ស្ទឹងស្លាគូ (ផ្លូវ-B)

3) ផ្លូវ-B ~ ខ្ពបស្វាយ (ផ្លូវ-C)

ការទទួលយកនូវការពិចារណានាពេលបច្ចុប្បន្ន និងសំរាប់លក្ខខ័ណ្ឌនាពេលអនាគតព្រមទាំងតំរូវការបន្ទាប់ពីការបញ្ចប់ការសាងសង់នៃកម្មវិធីផ្នែកខាងលើស្ទឹងស្លាគូ ហើយដែលកើតគោលបំណងនៃការពង្រីកប្រព័ន្ធផ្លូវបានសំរេចដូចតារាងសង្ខេបដូចខាងក្រោម :

**ស្តង់ដារផ្លូវ**

| ប្រភេទ | ផ្លូវ-A | ផ្លូវ-B | ផ្លូវ-C |
|---|---|---|---|
| បណ្តោយ (គ.ម) | 13.32 | 4.14 | 6.16 |
| ទទឹង (ម) | សរុប 5ម ប្រសិទ្ធិភាព 4 ម | សរុប 5ម ប្រសិទ្ធិភាព 4 ម | សរុប 4ម ប្រសិទ្ធិភាព3 ម |
| ល្បឿនគ្រោង | 30 គ.ម/ម៉ោង | 30 គ.ម/ម៉ោង | 20 គ.ម/ម៉ោង |
| បរិមាណចរាចរ (ផ្ទុកសំភារៈធ្ងន់ៗ) | 15~40 គ្រឿងក្នុងមួយថ្ងៃ | 15~40 គ្រឿងក្នុងមួយថ្ងៃ | តិចជាង 15 គ្រឿង |
| ទំរង់នៃផ្ទៃ និង បាតគ្រឹះ | សរុបកំពស់ 0.65ម (សំភារៈសាងសង់ក្នុងតំបន់) គ្រួសក្រហម 10 សម ខ្សាច់ និង គ្រួស 20សម | សរុបកំពស់ 0.65ម (សំភារៈសាងសង់ក្នុងតំបន់) គ្រួសក្រហម 10 សម ខ្សាច់ និង គ្រួស 20សម | កំពស់សរុប 0,65 ម (សំភារៈសាងសង់ក្នុងតំបន់) គ្រួសក្រហម 15 សម |
| ការការពារជើងទេរ | រៀបជើងទេរឡើងវិញ ឬ ដាំស្មៅ | រៀបជើងទេរឡើងវិញ ឬ ដាំស្មៅ | រៀបជើងទេរឡើងវិញ ឬ ដាំស្មៅ |
| គំរោងការណ៍ CBR | 3 | 3 | 2 |

71. **សហគមន៍កសិករប្រើប្រាស់ទឹក ( ស.ក.ប.ទ)**

<u>លក្ខណៈទូទៅ</u> : អាស្រ័យនៅលើគោលនយោបាយរបស់ក្រសួងធនធានទឹក និង ឧតុនិយម លើ ស.ក.ប.ទ ស.ក.ប.ទ មួយតំរូវឱ្យចាត់ចែងប្រតិបត្តិការ និង ការថែទាំ (O&M) នៃសំណង់ប្រព័ន្ធស្រោចស្រពទាំងអស់ដោយខ្លួនគេផ្ទាល់នូវតួនាទីទាំងពីរ គឺលក្ខណៈបច្ចេកទេស និង ថវិកាទាំងអស់ បន្ទាប់ពីសំណង់ទាំងអស់ត្រូវបានរៀបចំរួចរាល់សំរាប់ប្រតិបត្តិការ ហើយនិងបរិមាណរបស់វាដែលអាចចាត់ទុកថាវាល្មមគ្រប់គ្រាន់សំរាប់ O&M នៃសំណង់ទាំងអស់ដែលប្រគល់ដោយក្រសួងធនធានទឹក និង ឧតុនិយម នៅពីក្រោយគោលនយោបាយនេះមានគោលការណ៍ពីរគឺ : i) ការកាត់បន្ថយនូវបន្ទុកថវិកាដ៏ធ្ងន់ធ្ងររបស់ក្រសួងធនធានទឹក និង ឧតុនិយមតាមដែលអាចធ្វើទៅបាននៅលើការងារប្រតិបត្តិការ និងការថែទាំនៃសំណង់ប្រព័ន្ធស្រោចស្រពទាំងអស់នៅគ្រប់កំរិតនៃខ្នាតធំ និង មធ្យមរបស់គំរោងប្រព័ន្ធស្រោចស្រព (ច្រើនជាង 200 ហ.ត) នៅក្នុងប្រទេសកម្ពុជា ។ ii) គ្រប់កសិករ ឬ អ្នកទទួលផលប្រយោជន៍ទាំងអស់ត្រូវតែព្យាយាមស្វះស្វែងនៅក្នុងការចាត់ចែងនូវប្រតិបត្តិការ និងការថែទាំនូវសំណង់ស្រោចស្រព ដោយខ្លួនឯងផ្ទាល់ ដោយគ្មានការគាំទ្រផ្នែកបច្ចេកទេស ឬ ហិរញ្ញវត្ថុ ពីក្រសួងធនធានទឹក និង ឧតុនិយម ដែលជាការ

គ្រប់គ្រងដោយឯករាជ្យនូវនិរន្តភាពរបស់ស្ថាប័នមួយដោយមានការទុកចិត្តដោយខ្លួនឯង ។

72. **<u>ការវិភាគលើបញ្ហានៃ ស.ក.ប.ទ សំរាប់ផ្នែកតំបន់ខាងលើស្ទឹងស្លាគូ (USP)</u>** :

FWUCs បញ្ហាជាច្រើនដែលជាប់ទាក់ទងនឹងផ្ទៃដីនៅក្នុងកិរិតបច្ចេកទេស និង ថវិកា ។ សំរាប់កិរិតនៃថវិកាសហគមន៍កសិករប្រើប្រាស់ទឹកទាំងអស់ ដែលមានស្រាប់បានទទួលរងនូវការជួលរលំ ដោយសារតែមានការខ្វះខាតនូវថវិកា ។ ការងារថែទាំនៃសំណង់ស្រោចស្រពមិនអាចប្រព្រឹត្តទៅបានល្អ យោងទៅលើភាពខ្វះខាតនៃថវិកាប្រតិបត្តិការផងទាំងឡាយ ។ តំលៃស្រូវ គឺជាកត្តាខាងក្រៅមួយដែលមិនអាចគ្រប់គ្រងបាន ហើយដែលមានតំលៃយ៉ាងទាបក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។ ដូច្នេះហើយ គឺជាការលំបាកដែលកើតឡើងចំពោះវិភាគទានសេវាប្រើប្រាស់ទឹក ដោយសារថាកសិករទាំងអស់នៅក្នុងតំបន់ផ្នែកខាងលើស្លាគូ (USP) គឺភាគច្រើនជាកសិករធ្វើស្រែហើយ USP បានស្ថិតនៅក្នុងស្ថានភាពបែបនេះ ។ ការវិភាគនៅលើថវិកាហិរិញ្ញវត្ថុតំបូងបានបង្ហាញថា វិភាគទានសេវាកម្មប្រើប្រាស់ទឹកមិនអាចគ្រប់គ្រាន់ក្នុងការចំណាយផ្សេងៗសំរាប់ប្រតិបត្តិការរបស់ ស.ក.ប.ទ បានឡើយ ។ ដូច្នេះហើយប្រភពថវិកាផ្សេងៗ ត្រូវតែធ្វើការពិចារណានៅក្នុងការសិក្សានេះ ការលើកគំរោងរបស់ ស.ក.ប.ទ ត្រូវតែមានតួនាទីមួយសំរាប់ជាជំនួយក្នុងការរកទីផ្សារ ដើម្បីបន្ថែមការងារដ៏សំខាន់មួយនៃការងារប្រតិបត្តិ និង ការថែទាំនូវសំណង់ស្រោចស្រពទាំងអស់ ។ ដូច្នេះហើយ ស.ក.ប.ទ ត្រូវតែផ្តល់នូវកន្លែងទីផ្សារមួយសំរាប់សមាជិកទាំងអស់របស់ខ្លួន ដើម្បីនឹងលក់នូវផលិតផលដំណាំរួមផ្សំរបស់គាត់ទៅឱ្យឈ្មួញកណ្តាល ឬក៏អ្នកទិញផ្សេងៗ ។ ការទទួលបាននូវប្រាក់កំរៃលើការលក់ដូរផលដំណាំរបស់កសិករ និងឈ្មួញ គឺសំរាប់បំពេញនូវភាពខ្វះខាតនៃថវិកាសំរាប់ប្រតិបត្តិការនៃ ស.ក.ប.ទ ។

73. សំរាប់កិរិតបច្ចេកទេសក្នុងខណៈដែល ស.ក.ប.ទ មួយមានការលំបាក គឺគ្រប់កាលវេលាទាំងអស់ គឺពឹងផ្អែកទៅលើ ក្រ.ធ.ទ.ឧ ដើម្បីដោះស្រាយនូវការងារនេះ ។ បើទោះជាយ៉ាងនេះក្តី ក្រ.ធ.ន.ឧ មិនអាចទទួលខុសត្រូវគ្រប់ពេលវេលាឡើយទៅលើសំណើទាំងអស់ អាស្រ័យដោយភាពខ្វះខាតនៃប្រភពថវិកា និងបុគ្គលិកបច្ចេកទេស ហើយដែលជាបុព្វហេតុចុងក្រោយបំផុតនៃការខូចខាតបន្តិចម្តងៗនៃសំណង់ស្រោចស្រពទាំងអស់ ។ ដូច្នេះដើម្បីនឹងពង្រឹងនូវកំលាំងចិត្តនូវភាពជឿជាក់លើខ្លួនឯងនៃ ស.ក.ប.ទ បំលាស់ប្តូរមួយទៅដល់ចិត្តគំនិតរបស់កសិករ វាជាប្រការដ៏សំខាន់ បើទោះណាជាវាត្រូវការរយៈពេលមួយដ៏វែងក៏ដោយ ។ នៅក្នុងគោលបំណងនេះវាជាការលើកគំរោងមួយដែល ក្រ.ធ.ន.ឧ ត្រូវតែគាំទ្រយ៉ាងពេញទំហឹងឈានទៅបង្កើតនូវភាពរឹងប៉ឹងមួយនៃ ស.ក.ប.ទ នៅក្នុងខណៈពេលដែលស្របជាមួយ និងដំណាក់កាលនៃ គ្រោងការណ៏លំអិត និងការសាងសង់ព្រមទាំងរួមបញ្ចូល និងដំណាក់កាលប្រតិបត្តិការដំបូងនៃតំបន់ USP តាមរយៈការិយាល័យគំរោងដើម្បីនឹងបង្កើតឡើងនៅក្នុង USP ជាភ្នាក់ងារអនុវត្តន៏មួយក្រោមការគ្រប់គ្រងរបស់ការិយាល័យកណ្តាលនៃ ក្រ.ធ.ន.ឧ ។ ឯការិយាល័យគំរោងត្រូវតែបង្កើតឡើងជាមួយនិងបុគ្គលិកចាំបាច់ដែលកំណត់ដោយ ក្រ.ធ.ន.ឧ និង ម.ធ.ន.ឧ ខេត្តតាកែវ ព្រមទាំងភ្នាក់ងារផ្សេងៗទៀតដែលមានការពាក់ព័ន្ធ ។

74. **រចនាសម្ព័ន្ធកសិករប្រើប្រាស់ទឹក ( ស.ក.ប.ទ) :**

ទំរង់រចនាសម្ព័ន្ធនៃ ស.ក.ប.ទ សំរាប់ USP ត្រូវបានពិភាក្សាជាមួយគ្រប់បណ្តាមេឃុំទាំងអស់ និងជាមួយមេភូមិមួយចំនួនដែលទំរង់រចនាសម្ព័ន្ធនេះ ត្រូវតែមានក្រុមកសិករប្រើប្រាស់ទឹកទាំងអស់ (ស.ក.ប.ទ) ដែលត្រូវបង្កើតឡើងនៅលើគ្រប់ប្រឡាយស្រោចស្រពទាំងអស់ និង 6 ស.ក.ប.ទ (ដែលហៅថា ស.ក.ប.ទ.ប.រ) នៅលើប្រឡាយរងព្រមទាំង ស.ក.ប.ទ ជាន់ខ្ពស់ ដែលស្ថិតនៅកំពូលលើគេបង្អស់ (មើល **Figure IV-5.4.1**) ។ ចំពោះគណៈកម្មាការជាន់ខ្ពស់ គឺជាអ្នកគ្រប់គ្រងនូវរចនាសម្ព័ន្ធផ្នែកខាងលើបំផុត ហើយដែល មានបួនផ្នែកទៀតស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនដែលមានប្រធាន អនុប្រធាន និង លេខាធិការ ព្រមទាំងផ្នែកគណនេយ្យ រដ្ឋបាល ទីផ្សារ ប្រតិបត្តិការ និង ការថែទាំ និងផ្នែកដោះស្រាយវិវាទផងដែរ ។ ចំពោះផ្នែកប្រតិបត្តិការ និង ការថែទាំនឹងត្រូវគ្រប់គ្រងដោយផ្ទាល់នៅលើអាងទឹកទាំងអស់ព្រមទាំងប្រលាយ មេនៅផ្នែក USP ព្រមទាំងត្រួតពិនិត្យនៅលើគ្រប់អ្នកប្រតិបត្តិការប្រព័ន្ធ ។ ចំពោះ ស.ក.ប.ទ.ប.រ នីមួយៗ នឹងត្រូវចាត់ចែងដោយខ្លួនឯងនៅលើប្រលាយរងនីមួយៗ ។ ចំពោះ ស.ក.ប.ទ.ប.រ មួយៗ គឺមានក្រុម ស.ក.ប.ទ ចំនួន 4 ឬ 5 ដែលនឹងចាត់ចែងនៅលើប្រលាយស្រោចស្រព និង ភ្លឺស្រែ (ផ្លូវទឹក) ជាមួយនិងទំហំផ្ទៃដីជាមធ្យម 33 ហ.ត ។ ចាប់តាំងតែពីការបញ្ចប់នូវការបង្កើត ស.ក.ប.ទ និងការងាររបស់គំរោង ការិយាល័យគំរោងនឹងត្រូវកាត់បន្ថយឱ្យទៅជាផ្នែកប្រឹក្សាតូចមួយដែលហៅថាផ្នែកគាំទ្រ និង ត្រួតពិនិត្យបច្ចេកទេស (TSAU) ។ ស.ក.ប.ទ សំរាប់ USP នឹងប្រព្រឹត្តទៅក្រោម TSAU សំរាប់បួនឆ្នាំដំបូងដែលជាការចូលរួមក្នុងការគ្រប់គ្រង ។ បន្ទាប់ពីការចូលរួមក្នុងការគ្រប់គ្រង ស.ក.ប.ទ ត្រូវតែចាត់ចែងលើគ្រប់ការងារប្រតិបត្តិការ និង ការថែទាំដោយខ្លួនឯង ។

75. **តំលៃថ្លៃសេវាថែទាំ និង ប្រតិបត្តិការប្រចាំឆ្នាំ** :

ដើម្បីនឹងកំណត់នូវតំលៃសេវាកម្មប្រើប្រាស់ទឹកសំរាប់ USP ចំណូល និងការចំណាយប្រចាំឆ្នាំនៅលើប្រតិបត្តិការ និង ការថែទាំដែលមិនរួមបញ្ចូលនូវតំលៃគ្រឿងបន្លាស់ផ្សេងៗត្រូវបានគណនា ។ តំរូវការបុគ្គលិកនៃ ស.ក.ប.ទ សំរាប់ប្រតិបត្តិការ និង ការថែទាំ នៃតំបន់ USP ត្រូវបានគណនាឃើញថាមានចំនួន 118 នាក់ (មើល **Figure IV-5.4.1**) ។ តំលៃប្រតិបត្តិការ និង ការថែទាំប្រចាំឆ្នាំនៃ ស.ក.ប.ទ ត្រូវបានគណនាប្រមាណមើលសំរាប់ធ្វើឱ្យមានភាពសមរម្យក្នុងការចាត់ចែងទឹករបស់ ប្រព័ន្ធដែលបង្ហាញនៅក្នុង **Table IV-5.4.2** ហើយត្រូវបានបូកសរុបដូចតទៅ :

| | |
|---|---|
| ការចំណាយលើបុគ្គលិក : | 99,2 លានរៀល |
| ការចំណាយលើការងារប្រតិបត្តិ និង ការថែទាំ : | 64,4 លានរៀល |
| សរុប : | 163,6 លានរៀល |

76. **ប្រាក់ចំណូល** :

ដើម្បីគ្រប់គ្រងទៅលើការចំណាយប្រចាំឆ្នាំខាងលើសំរាប់ប្រតិបត្តិការ និង ការថែទាំរបស់ ស.ក.ប.ទ

នៃ USP អត្រាភាគទានសេវាកម្មប្រើប្រាស់ទឹកត្រូវបានប៉ាន់ប្រមាណនៅក្នុងកំរិតតំលៃ 140 គ.ក/ហ.ត សំរាប់ការធ្វើស្រែ ឬក៏ 40.600 រៀល/ហ.ត សំរាប់ទាំងរដូវប្រាំង និង រដូវវស្សា ។ ដោយឡែកសំរាប់ដំណាំរួមផ្សំនានា គឺ 76.500 រៀល / ហ.ត ឬក៏ 264 គ.ក/ហ.ត ស្រូវដែលបង្ហាញនៅក្នុងតារាងជាបន្តបន្ទាប់នូវប្រាក់ចំណូលប្រមាណ 204,5 លានរៀល ។ ការប្រមូលបាន 80 % នៃអត្រាប្រមូលសរុប គឺមានប្រមាណ 163,6 លានរៀល ដែលសមមាត្រទៅតំលៃប្រតិបត្តិការ និង ការថែទាំប្រចាំឆ្នាំ ។

**ចំនួននៃចំណែកភាគទានសេវាប្រើប្រាស់ទឹកដែលសមមាត្រទៅនឹងតំលៃប្រតិបត្តិការ និង ការថែទាំ**

| ការដាំដុះ | ឯកត្តា | ផ្ទៃដី | ថ្លៃសេវាប្រើប្រាស់ទឹកដែលអាចបាន<br>រៀល / ហ.ត | សរុប<br>លានរៀល | តុល្យភាពនៃស្រូវ (290 រៀល/គ.ក)<br>គ.ក/ហ.ត |
|---|---|---|---|---|---|
| - ស្រូវ | ហ.ត | 3,500 | 40,600 | 142.10 | 140 |
| - ដំណាំរួមផ្សំរដូវវស្សា | ហ.ត | 500 | 40,600 | 20.30 | 140 |
| - ដំណាំរួមផ្សំរដូវប្រាំង | ហ.ត | 550 | 76,500 | 42.08 | 264 |
| សរុប | | | | 204.48 | |
| តំលៃសេវាទឹកដែលប្រមូលបាន (80%) | | | | 163.58 | |

77. **ការកំណត់ថ្លៃសេវាប្រើប្រាស់ទឹក ISF** :

គឺវាជាការដាក់សំណើសំរាប់កំណត់នូវតំលៃសាកល្បង 140 គ.ក/ហ.ត សំរាប់ការដាំស្រូវគឺប្រហែលស្មើ 40.600រៀល ព្រមទាំងដំណាំរួមផ្សំនារដូវវស្សា ដោយឡែកតំលៃ 76.500 រៀល សំរាប់ដំណាំរួមផ្សំនារដូវប្រាំង ហើយសំរាប់ USP តំលៃនេះសំរាប់តែការងារប្រតិបត្តិការ និង ការថែទាំប៉ុណ្ណោះ ។ ប្រសិនបើថ្លៃសេវាប្រើប្រាស់ទឹកគ្របដណ្តប់ទាំងស្រុងទៅលើតំលៃនៃការថែទាំ និង បំលាស់ប្តូរ (ទ្វារទឹកទាំងអស់ សំភារៈការិយាល័យ ។ល។) ការបន្ថែមតំលៃសេវាប្រើប្រាស់ទឹក 1,55 ដង (218 គ.ក/ហ.ត ស្រូវ ឬ តំលៃដែលស្មើ) វាជាការចាំបាច់ ។ ម៉្យាងវិញទៀតការបង្កើនថ្លៃសេវាប្រើប្រាស់ទឹក 78 គ.ក / ហ.ត សំរាប់ការដាំស្រូវ និងប្រហែលស្មើ 22.330 រៀល សំរាប់ដំណាំរដូវវស្សា ព្រមទាំង 42. 075 រៀល សំរាប់ដំណាំរួមផ្សំរដូវប្រាំងវាជាប្រការចាំបាច់ ។ ហើយប្រសិនបើគ្មានថវិកាចាប់ផ្តើមពីដំបូងទេ ស.ក.ប.ទ នឹងមិនអាចគ្រប់គ្រាន់សំរាប់តំលៃសរុបនៃការងារប្រតិបត្តិការ និង ការថែទាំបានឡើយ ដើម្បី បំពេញនូវតុល្យភាពនៃកង្វះខាតខាងលើ គឺត្រូវស្នើកំណត់យកនូវការចាប់ផ្តើមនៃសកម្មភាពទីផ្សារសំរាប់ផលិត ផលកសិកម្មនៅក្នុងកិច្ចដំណើរការរបស់ ស.ក.ប.ទ នៅតំបន់ខាងលើស្ទឹងស្លាគូ (USP) ។

78. **ការបង្កើត ស.ក.ប.ទ សំរាប់តំបន់ USP** :

ស.ក.ប.ទ សំរាប់តំបន់ USP នឹងមានប្រហែល 4020 គ្រួសារ នៅក្នុង 32 ភូមិ ។ ដំណើរការនៃការបង្កើត ស.ក.ប.ទ គឺបានពិភាក្សាជាមួយបណ្តាមេភូមិដែលផ្តោតសំខាន់ ទៅលើមតិយោបល់នៃដំណើរការបង្កើតដែលស្ថិតនៅក្នុងប្រកាស 306 ព្រមជាមួយនូវការពិពណ៌នាខាងក្រោម ចំនួន 8 ដំណាក់កាល (មើល **Figure IV-5.4.2** និង **Figure IV-5.4.3**) ។ ការិយាល័យរបស់គំរោងនឹងជួយដល់

កសិករទាំងអស់នៅក្នុងការបង្កើត ស.ក.ប.ទ ក្រោមការត្រួតពិនិត្យបច្ចេកទេសពី ក្រ.ធ.ន.ឧ ព្រមទាំងគាំទ្រផ្នែកថវិកាផងដែរ ។ កសិករជាច្រើនពុំមានទម្លាប់ក្នុងការបង្កើតក្រុមកសិករឡើយ ។ សៀវភៅចុះបញ្ជីចំនួនពលរដ្ឋក្នុងតំបន់ (Cadaster) និងផែនទីភូមិសាស្ត្រតាមតំបន់ (Map Cadaster) គឺពុំមានឡើយ ។ បើទោះជាយ៉ាងនេះក្តីវាត្រូវការពេលវេលាមួយសំរាប់គ្រប់កសិករទាំងអស់ដើម្បីឱ្យបានយល់ដឹងពី ស.ក.ប.ទ ហើយធ្វើការបង្កើតឡើង ។ ចំពោះពេលវេលាដែលចាំបាច់សំរាប់ការបង្កើតបានប៉ាន់ប្រមាណមើលមានរយៈពេលប្រហែល 3 ឆ្នាំដែល :

**ដំណាក់កាលទី -1:** ការធ្វើឱ្យមានការយល់ដឹងគ្រប់កសិករទាំងអស់ (8 ខែ)

**ដំណាក់កាលទី -1:** ការរៀបចំនៃផ្នែកប្រលាយស្រោចស្រពនៃ ស.ក.ប.ទ (11 ខែ)

**ដំណាក់កាលទី -1:** ការបោះឆ្នោតនៃក្រុមកសិករប្រើប្រាស់ទឹក (ស.ក.ប.ទ) (4 ខែ)

**ដំណាក់កាលទី -1:** ការបង្កើត ស.ក.ប.ទ ប្រលាយរង (3 ខែ)

**ដំណាក់កាលទី -1:** ការបង្កើតគណកម្មាការជាន់ខ្ពស់ (Apex) និងការចាប់ផ្តើមនៃការចូលរួមក្នុងការងារសាងសង់ (3 ខែ)

**ដំណាក់កាលទី -1:** ការរៀបចំ និងបញ្ចប់ពង្រៀង លក្ខន្តិកៈនៃ ស.ក.ប.ទ (6 ខែ)

**ដំណាក់កាលទី -1:** ការធ្វើសត្យាប័នចុងក្រោយនៃលក្ខន្តិកៈ ស.ក.ប.ទ (1 ខែ)

**ដំណាក់កាលទី -1:** ការចុះបញ្ជី ស.ក.ប.ទ (2,5 ខែ)

79. **ការអភិវឌ្ឍន៍ស្ថាប័ន និង កម្មវិធីកសាងសមត្ថភាព**

ដើម្បីនឹង i) ឱ្យមានភាពរលូននៅក្នុងការបង្កើត ស.ក.ប.ទ ii) ដើម្បីនិរន្តភាពនៃដំណើរការហិរញ្ញវត្ថុ និងបច្ចេកទេសប្រតិបត្តិការនៃ ស.ក.ប.ទ iii) ដើម្បីធ្វើឱ្យបានចប់សព្វគ្រប់នូវការបង្កើនប្រាក់ចំណូលសំរាប់កសិករ ការអភិវឌ្ឍន៍ស្ថាប័ន និងកម្មវិធីកសាងសមត្ថភាព វាជាប្រការចាំបាច់សំរាប់តំបន់ផ្នែកខាងលើស្ទឹងស្លាគូ (USP) ។ សំរាប់ការងារនេះវាជាការកំណត់សំណើមួយដែល ក្រ.ធ.ន.ឧ ត្រូវបញ្ជូនអ្នកជំនាញផ្នែកអភិវឌ្ឍន៍ស្ថាប័ន និងកសាងសមត្ថភាពសំរាប់រយៈពេល 6ឆ្នាំ ក្នុងដំណាក់កាល ការកំណត់សំណើសំរាប់អនុវត្តកម្មវិធីជាដំបូង គឺបញ្ជូនអ្នកជំនាញដែលនឹងផ្តល់ដល់ការហ្វឹកហ្វឺនដល់បុគ្គលិកនៃការិយាល័យគំរោង ហើយបន្ទាប់មកទៀតបុគ្គលិកការិយាល័យដែលបានហ្វឹកហ្វឺនរួចហើយនឹងផ្តល់នូវការហ្វឹកហ្វឺននេះទៅដល់គ្រប់កសិករ និងបុគ្គលិករបស់ ស.ក.ប.ទ (មើល **Figure IV-5.5.1** និង **Figure IV-5.5.2.**) ។

**(1) <u>កម្មវិធីផ្តល់ដល់បុគ្គលិកការិយាល័យគំរោង</u>** : កម្មវិធីនេះគឺសំរាប់ការកសាងសមត្ថភាពនៃបុគ្គលិកដែលមាននៅក្នុងការិយាល័យគំរោងដែលមានពីរប្រភេទ :

1) ផែនការ និងគំរោងការណ៍សំរាប់រយៈពេល 1,5 ឆ្នាំ នៅដំណាក់កាលគ្រោងប្លង់លំអិត និងការត្រួតពិនិត្យបច្ចេកទេសនៃសំណង់ស្រោចស្រព សំរាប់រយៈពេល 2,5 ឆ្នាំ ក្នុងដំណាក់កាលនៃការសាងសង់ ។
2) ស.ក.ប.ទ និងការងារពាក់ព័ន្ធទាំងអស់ ដូចជាការបង្កើត ស.ក.ប.ទ និងដំណើរការការអភិវឌ្ឍន៍កសិដ្ឋាន ការគ្រប់គ្រង ស.ក.ប.ទ ប្រតិបត្តិការ និង ការថែទាំនូវសំណង់ស្រោចស្រព ការគាំទ្រដល់ផ្នែក

ទីផ្សារ និងការងារអនុវត្តន៍ជាក់ស្តែងទៅលើស្រែចំការ ។ល។ គឺសំរាប់រយៈពេល 6 ឆ្នាំ សរុបដែលគិតចាប់តាំងពីដំណាក់កាលគ្រោងលំអិត រហូតដល់ដំណាក់កាលនៃការចាប់ផ្តើមប្រតិបត្តិការដំបូង ។

អ្នកជំនាញបរទេស និងក្នុងស្រុកត្រូវបានស្នើឱ្យផ្តល់នូវការហ្វឹកហ្វឺនសំរាប់បុគ្គលិកការិយាល័យគំរោង និងជួយដល់ពួកគេនូវការរៀបចំនូវក្បួនគំរា និងក្បួនណែនាំ ដែលចាំបាច់សំរាប់ហ្វឹកហ្វឺនដល់កសិករទាំងអស់ និងបុគ្គលិករបស់ ស.ក.ប.ទ ដូចខាងក្រោមនេះ :

- ក្បួនណែនាំសំរាប់ការបង្កើត ស.ក.ប.ទ
- ក្បួនគំរានៃការគ្រប់គ្រង ស.ក.ប.ទ
- ក្បួនគំរាសំរាប់ការអភិវឌ្ឍន៍ការងារស្រែចំការ
- ក្បួនគំរាសំរាប់ប្រតិបត្តិការ និង ការថែទាំនូវសំណង់ស្រោចស្រពទាំងអស់
- ក្បួនគំរាសំរាប់ការអនុវត្តន៍ជាក់ស្តែងលើការងារស្រែចំការ
- ក្បួនគំរាសំរាប់ការងារទីផ្សារ

(2) **<u>កម្មវិធីចំពោះកសិករ និង បុគ្គលិក ស.ក.ប.ទ</u>** : កម្មវិធីហ្វឹកហ្វឺនចំពោះកសិករ និង បុគ្គលិក ស.ក.ប.ទ ដែលមាន 6 វគ្គបណ្តុះបណ្តាលដូចនេះ :

- ស.ក.ប.ទ និងការបង្កើតវាឡើងដោយកសិករ ( ប្រហែល 4020 គ្រួសារ)
- ការអភិវឌ្ឍន៍ទៅលើការងារស្រែចំការសំរាប់បុគ្គលិក ស.ក.ប.ទ ( សរុប 72 នាក់)
- ការគ្រប់គ្រងនៃ ស.ក.ប.ទ ចំពោះបុគ្គលិក ស.ក.ប.ទ ( សរុប 22 នាក់)
- ការងារប្រតិបត្តិការ និងការថែទាំសំណង់ស្រោចស្រពសំរាប់បុគ្គលិករបស់ ស.ក.ប.ទ ( សរុប 82នាក់)
- ការងារទីផ្សារចំពោះបុគ្គលិក ស.ក.ប.ទ ( សរុប 10 នាក់)
- ការអនុវត្តន៍ជាក់ស្តែងលើការងារស្រែចំការ (120 នាក់នៃប្រធានក្រុមកសិករ)

80. **កម្មវិធីការពារបរិស្ថាន**

ការប៉ះពាល់ខ្លះៗជាអវិជ្ជមាននៅលើបរិស្ថាន ដែលបានចង្អុលបង្ហាញតាមរយៈការធ្វើពិសោធន៍នៅលើបរិស្ថានដំបូង (IEE) ។ តែទោះជាយ៉ាងនេះក្តីវាមិនមែនជាភាពសំខាន់ណាស់ណាទេ ហើយភាពសំខាន់ភាគច្រើនអាចនឹងកាត់បន្ថយ ឬក៏ធ្វើឱ្យមានភាពអប្បបរមាដោយការកំណត់សំណើបរិមាណវាស់ស្ទង់ដូចជាភាពសំរបសំរួលនៃគុណភាពទឹក និងការសំរបសំរួលនៃលក្ខខ័ណ្ឌនៃមេរោគកើតចេញពីទឹកព្រមទាំងចំណូលកសិកម្មផងដែរ ។

81. **ស្ថាប័នប្រតិបត្តិ**

(1) **កម្មវិធីផ្នែកខាងលើតំបន់ស្ទឹងស្លាគូ** (USP) : អាទិភាពដើម្បីអនុវត្តន៍ការិយាល័យគំរោងមួយនឹងត្រូវបង្កើតឡើងដោយឯករាជ្យទៅតាមបណ្តោយផ្លូវលេខ 33 ក្នុងតំបន់ផ្នែកខាងលើស្ទឹងស្លាគូ ក្នុងភូមិអង្គរការ ឃុំតាភេម ។ ការិយាល័យរបស់គំរោងនឹងត្រូវបង្កើតឡើងក្រោមការគ្រប់គ្រងរដ្ឋបាលដោយផ្ទាល់ពី ក្រ.ធ.ទ.ឧ ហើយក្រសួងនឹងចាត់តាំងអ្នកគ្រប់គ្រងដោយផ្ទាល់ ។ ការិយាល័យគំរោងនឹងមាន 4 ផ្នែក ដោយដាក់ឈ្មោះថា

ផ្នែករដ្ឋបាល បច្ចេកទេស សហគម និងផ្នែកកំលាំងការងារដែលមាន i) បុគ្គលិកបច្ចេកទេស ii) បុគ្គលិករដ្ឋបាលនឹងត្រូវបានកំណត់ចាត់តាំង ។ អ្វីដែលសំរាប់ការិយាល័យ និង សំភារៈប្រតិបត្តិការរថយន្តដែលមានកាឡេបូន 1 ម៉ូតូចំនួន 8 វិទ្យុទាក់ទង និងម៉ាស៊ីនភ្លើងមួយ ។ល។ នឹងត្រូវទិញបញ្ចូល ។ បន្ទាប់ពីបញ្ចប់ការងារសាងសង់ផ្នែកត្រួតពិនិត្យ និងគាំទ្របច្ចេកទេសនឹងត្រូវទទួលខុសត្រូវផ្តល់ដល់ ស.ក.ប.ទ ទាំងអស់នូវការងារប្រតិបត្តិការ និង ការថែទាំសំរាប់រយៈពេល 4 ឆ្នាំ ។ វិស្វករជំនាញពីររូបមកពី ក្រ.ធ.ទ.ឱ និងអ្នកជំនាញម្នាក់មកពីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ ហើយអ្នកផ្សេងៗទៀតដែលជាប់ទាក់ទងនឹងការិយាល័យរបស់រដ្ឋាភិបាល ត្រូវបានកំណត់តែងតាំងនៅក្នុងផ្នែកនេះ (**Figure IV-6-1-1**) ។

**(2) កម្មវិធីសាងតូចៗ (SRP) និងកម្មវិធីអភិវឌ្ឍន៍ស្រះទឹក (PDP)** : ការពិចារណាទៅលើការអភិវឌ្ឍន៍ទំហំ ខ្នាត និងចំណេះដឹង ឬ បទពិសោធន៍នៃ ម.ធ.ទ.ឱ ខេត្តតាកែវ ការអនុវត្តន៍ទៅលើ SRP ត្រូវកំណត់ស្នើដើម្បីនឹងចាត់ចែងគ្រប់គ្រងដោយ ម.ធ.ទ.ឱ ខេត្តតាកែវដែលជាផ្នែកមួយនៃការងារប្រចាំ ។ ការណែនាំបច្ចេកទេសផ្សព្វផ្សាយ និង គាំទ្រនឹងប្រព្រឹត្តទៅជាមួយនឹងកិច្ចសហការ និងសំរបសំរួលគ្នាជាមួយភ្នាក់ងារផ្សេងៗ ។ PDP នឹងប្រព្រឹត្តទៅជាមួយនិងការគាំទ្របច្ចេកទេសដល់អ្នកប្រើប្រាស់ស្រះជាក្រុម ហើយនិងគ្រប់គ្រងថវិកា PDP ដោយ ម.ធ.ទ.ឱ ខេត្តតាកែវ ។

82. **កម្មវិធីអនុវត្តន៍**

**(1) USP** : ការងារសាងសង់នៃ USP នឹងត្រូវចំណាយពេលធ្វើ 2 ឬ 2ឆ្នាំកន្លះ នារដូវប្រាំង (មើល **ទំរង់ IV-6.2.1**) ។ ការសាងសង់នូវប្រលាយបង្ហៀរ ឬ ប្រលាយមេនឹងត្រូវបញ្ចប់នៅក្នុងឆ្នាំទី 1 បន្ទាប់មកអាងទឹកប្រលាយរង ប្រលាយស្រោចស្រពនឹងត្រូវប្រព្រឹត្តទៅសំរាប់បំពេញក្នុងរយៈពេលសាងសង់ ។ ការសាងសង់អាងទឹក ប្រលាយបង្ហៀរ ឬ ក៏ប្រលាយមេនឹងត្រូវធ្វើកុងត្រាតាមរយៈការដេញថ្លៃជាលក្ខណៈអន្តរជាតិ ដោយឡែកការអភិវឌ្ឍន៍នៃប្រលាយស្រោចស្រព ឬ ក៏ការអភិវឌ្ឍន៍ទៅលើកសិដ្ឋាននឹងត្រូវចុះកិច្ចសន្យាជាមួយនឹងការដេញថ្លៃនៅក្នុងស្រុក ។ ចំពោះវិធីសាស្រ្តនៃការចូលរួម វាជាការកំណត់សំណើដែលគ្រប់អ្នកដែលទទួលផលប្រយោជន៍ទាំងអស់ ត្រូវតែសាងសង់នូវភ្លឺភ្លោះ ឬក៏ផ្លូវទឹករបស់ពួកគេក្រោមការត្រួតពិនិត្យបច្ចេកទេសពីការិយាល័យគំរោង និង អ្នកទទួលផលប្រយោជន៍ត្រូវផ្តល់ដី ដែលត្រូវការសំរាប់ការសាងសង់នូវប្រលាយស្រោចស្រពទាំងឡាយ និងភ្លឺភ្លោះ ឬ ផ្លូវទឹក ។

**(2) SRP** : អាងទឹកចំនួនពីរ នៃ SRP នឹងត្រូវសាងសង់ក្នុងរយៈពេល 1 ឆ្នាំ (មើល **Figure IV-6.2.2** ជាបន្តបន្ទាប់) ។ ការងារសាងសង់នឹងត្រូវចុះកិច្ចសន្យាដោយការដេញថ្លៃជាលក្ខណៈក្នុងស្រុក ។ សមាសធាតុរបស់គំរោងគួរតែមានការសាងសង់នៃអាង និងសំណង់ពាក់ព័ន្ធ លើកលែងតែសំណង់ស្រោចស្រពនៅក្នុងផ្ទៃដីស្រោចស្រពដែលនឹងត្រូវព្យាយាមធ្វើដោយក្រុមកសិករប្រើប្រាស់ទឹក(ស.ក.ប.ទ)ដោយខ្លួនឯង ។

**(3) PDP**: PDP នឹងត្រូវអនុវត្តន៍នៅក្នុងបីដំណាក់កាលដែលកំណត់ស្នើនៅក្នុងគំរោងប្លង់មេដែលឱ្យឈ្មោះថាដំណាក់កាលអភិវឌ្ឍន៍ដំបូង (Pilot Development Stage) (ដំណាក់កាល 1) ដំណាក់កាលអភិវឌ្ឍន៍លំអិត (ដំណាក់កាល 2) និងដំណាក់កាលអភិវឌ្ឍន៍ដោយខ្លួនឯង (ដំណាក់កាល 3) ដែលគួរតែធ្វើ

ក្នុងរយៈពេល 10 ឆ្នាំ ។ ការអនុវត្តន៍កម្មវិធីសំរាប់ PDP បង្ហាញក្នុង **Figure IV-6.2.2** ។

**(4) RIP** : កម្មវិធីអភិវឌ្ឍន៍ផ្លូវ (RIP) : ផ្លូវចំនួនបីនៃ RIP នឹងត្រូវសាងសង់ឡើងដោយចំណាយរយៈពេល 2 ឆ្នាំ ។ ការងារសាងសង់នឹងត្រូវសាងសង់ដោយការដេញថ្លៃជាលក្ខណៈក្នុងស្រុក ។ គ្រោងការព្រមទាំងការសាងសង់នឹងត្រូវត្រួតពិនិត្យដោយក្រសួងអភិវឌ្ឍន៍ជនបទ ឬក៏មន្ទីរអភិវឌ្ឍន៍ជនបទ (MRD ឬ DRD) ។

83. **ចំណោងចំណាយ**

**(1) USP** : ចំនួនសរុបថ្លៃដើមវិនិយោគ USP មានតំលៃ 76.624,6លានរៀល បានបង្ហាញក្នុង **Table IV-6.3.1** និងសង្ខេបដូចខាងក្រោម :

**ថ្លៃដើមវិនិយោគ USP**

(ឯកតា : លានរៀល)

| រាយសេចក្តី | បរទេស (F/C) | ក្នុងស្រុក (L/C) | សរុប |
|---|---|---|---|
| 1)ការងាររៀបចំ | 2,484.9 | 846.3 | 3,331.2 |
| 2) ចំណាយសាងសង់ផ្ទាល់ | 30,633.5 | 14,238.0 | 44,871.5 |
| 3) បរិក្ខារ O&M | 156.7 | 10.3 | 167.0 |
| 4) អភិវឌ្ឍន៍ស្ថាប័ន | 666.9 | 1,760.8 | 2,427.7 |
| 5) ចំណាយការតាំងទីលំនៅថ្មី និង សំណង់ដី | 3.3 | 197.0 | 200.3 |
| 6) ចំណាយរដ្ឋបាល | 155.7 | 824.3 | 980.0 |
| 7) សេវាវិស្វកម្ម | 11,921.7 | 623.5 | 12,545.2 |
| 8) យថាភាព | 8,358.0 | 3,743.7 | 12,101.7 |
| ចំនួនសរុប | 54,380.7 | 22,243.9 | 76,624.6 |

**(2) SRP** : ចំនួនសរុបថ្លៃដើមវិនិយោគ SRP មានតំលៃ 474,4លានរៀល មាន 223,7លានរៀលទៅអាង 160 SRP និង 250,7លានរៀល សំរាប់កំសី SRP ។ មើល **Table IV-6.3.3** ។

**(3) PDP** : ចំនួនសរុបថ្លៃដើមវិនិយោគត្រពាំងស្នោរ PDP គឺ 180,5លានរៀល ។ មើល **Table IV-6.3.5** ។

**(4) RIP** : ចំនួនសរុបថ្លៃដើមវិនិយោគ RIP គឺ 4,175.1លានរៀល ។ មើល **Table IV-6.3.7**

84. **ការវាយតំលៃគំរោង**

ការវាយតំលៃសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានធ្វើឡើងចំពោះគំរោងអត្ថិភាព និងអត្រាចំណូលសេដ្ឋកិច្ចផ្ទៃក្នុង (EIRRs) (%) មានអត្រាដូចខាងក្រោម :

USP : 10.2 %

កំសី SRP : 13.7 %

អាង 160 SRP : 14.5 %

PDP : 8.7 %

RIP នៅ USP : 18.8 %

ការវិភាគថវិកាកសិកម្ម ត្រូវបានធ្វើឡើងដោយសន្មត់ពីបំរែបំរួលរំពឹងទុកក្នុងចំណូល និង ចំណាយសំរាប់បរិមាណមធ្យមរំពឹងទុកពីប្រតិបត្តិការកសិកម្មនៅតំបន់ USP SRP និងតំបន់ PDP ។ ចំណូលគ្រួសារបានប៉ាន់ស្មានថាកើនឡើងដល់ 99 % សំរាប់ USP 14-34 % សំរាប់ SRP និង 16 % សំរាប់ PDP ។ ថវិកាបំរុងសុទ្ធនាពេលអនាគតរបស់គ្រួសារកសិកម្ម ក្រោមស្ថានភាពមានគំរោង ត្រូវបានរំពឹងទុកថានឹងកើនឡើងជាពិសេសនៅតំបន់ USP ។ ពីព្រោះ SRP និង PDP អាចស្រោចស្រពនៅផ្នែកមួយនៃដីធ្វើស្រែពីកសិករ ផលប៉ះពាល់ហិរញ្ញវត្ថុចំពោះសេដ្ឋកិច្ច ការធ្វើស្រែរបស់តំបន់ទាំងនោះនឹងត្រូវគេគិតចំនួន ។ ស្ថានភាពចិញ្ចឹមជីវិតនាពេលអនាគតស្ថិតក្នុងស្ថានភាពពេលគ្មានគំរោង និងមានគំរោងបានសង្ខេបដូចខាងក្រោមនេះ :

**ការវាយតំលៃថវិកាកសិកម្មរបស់ការសិក្សាពីភាពអាចធ្វើបាន**

(ឯកតា: ពាន់រៀល)

| ភាយសេចក្តី | USP | SRP | | PDP |
|---|---|---|---|---|
| | | កំសី | អាង 160 | |
| ផ្ទៃដីមធ្យម (ហ.ត) | 0.87 | 1.33 | 1.10 | 1.15 |
| គ្មានគំរោង | | | | |
| ចំណូល | 875.5 | 1,502.2 | 1,034.7 | 1,065.6 |
| ចំណាយ | 866.2 | 1,330.2 | 983.7 | 961.7 |
| ទុនបំរុងសុទ្ធ | 9.3 | 172.0 | 51.0 | 103.9 |
| មានគំរោង | | | | |
| ចំណូល | 1,746.0 | 2,017.7 | 1,184.4 | 1,239.2 |
| ចំណាយ | 1,033.9 | 1,459.5 | 1,023.2 | 978.3 |
| ទុនបំរុងសុទ្ធ | 712.1 | 558.2 | 161.2 | 260.9 |
| កើនឡើង (%) | | | | |
| ចំណូល | 99 | 34 | 14 | 16 |
| ចំណាយ | 19 | 10 | 4 | 2 |
| ទុនបំរុងសុទ្ធ | 7,557 | 225 | 216 | 151 |

លើសពីនេះទៅទៀត i) សមត្ថភាពបង់ថ្លៃ O&M និង ii) សកម្មភាពការងារ O & M របស់ FWUC និងការគ្រប់គ្រង USP ត្រូវបានតាមដានការងារ ។ ជាលទ្ធផលអាចសន្និដ្ឋានបានថា គំរោងអត្ថិភាពទាំងអស់អាចសំរេចនូវលក្ខណៈសេដ្ឋកិច្ច និង លក្ខណៈហិរញ្ញវត្ថុ ។

85. **បន្ថែមពីនេះទៅទៀតផលប៉ះពាល់ប្រយោជន៍ និង សេដ្ឋកិច្ចសង្គមបានសន្និដ្ឋានទុកថា** :

(1) **ស្រូវនាំចេញផ្គត់ផ្គង់ដោយខ្លួនឯងក្នុងតំបន់គំរោង** : ការតំឡើងប្រាក់ប្រចាំឆ្នាំពីផលិតកម្មស្រូវនៅ USP SRPs ទាំងពីរ និងគំរោង PDP និងស្រូវប្រហែលជា 6.100 តោន និងអង្ករ 4.000 តោនក្រោមស្ថានភាពមានគំរោង ។ ផលិតកម្មស្រូវកើនឡើងនេះនឹងផ្គត់ផ្គង់ថែមទៀតសំរាប់ការខ្វះខាតតំរូវការអង្ករក្នុងស្រុក ។

(2) **ផលិតកម្មបន្លែ និង ការសម្បូរបែបវិយោគផ្សេងៗ** : បន្លែក្នុងតំបន់គំរោងបានផលិតសំខាន់សំរាប់គ្រួសារនឹងប្រើប្រាស់ក្នុងមូលដ្ឋាននាពេលបច្ចុប្បន្ននេះ ។ ក្រោយពេលអនុវត្តន៍គំរោង ការតំឡើងប្រាក់

ប្រចាំឆ្នាំរបស់ផលិតកម្មបន្លែនឹងកើនប្រហែល 3.500 តោន ដែលមានតំលៃស្មើ 2,4 ពាន់លានរៀល (0,6 លានដុល្លាអាមេរិក) នៅតំលៃនៅកសិដ្ឋាន ។ ផលិតកម្មបន្លែនាពេលអនាគត ពីគំរោងនឹងអាចជំនួសនីហរណកម្មបន្លែពីបណ្តាប្រទេសជិតខាង ។

(3) **ការកែលំអផ្លូវជនបទ** : USP និងផ្តល់ផ្លូវចំងាយ 44.7 គ.ម តាមបណ្តោយប្រឡាយរង ។ ផ្លូវទាំងនេះនឹងមានឥទ្ធិពលទៅលើសេដ្ឋកិច្ចមូលដ្ឋាន តាមរយៈមិនផ្ទាល់តែមួយគត់ដោយកាត់បន្ថយចំណាយដឹកជញ្ជូន ប៉ុន្តែក៏អាចសន្សំសំចៃពេលវេលាបានផងដែរសំរាប់ការដឹកជញ្ជូន និងការបាត់បង់អប្បបរមាក្រោយពេលច្រូតកាត់កសិផល ។ល។

(4) **បង្កើនឱកាសរកការងារធ្វើ** : គំរោងនេះនឹងត្រូវការកំលាំងការងារបន្ថែមទៀតប្រហែល 134ពាន់នាក់ក្នុងមួយថ្ងៃ ប្រចាំឆ្នាំសំរាប់ការងារធ្វើស្រែ ។ លើសពីនេះកំលាំងពលកម្មសាងសង់សំរាប់ USP នឹងមានមនុស្សសរុបប្រហែល 303.8លាននាក់ ក្នុងមួយថ្ងៃ ។ ក្នុងកំឡុងពេលសាងសង់ពីឆ្នាំ 2003 – 2005 កំលាំងពលកម្មប្រហែល 580 នាក់នឹងត្រូវធ្វើការរាល់ថ្ងៃជាមធ្យមក្នុងរយៈពេលសាងសង់ជាក់ស្តែង ក្នុងរយៈពេល 21ខែ ។ កំលាំងការងារបន្ថែមទៀតនឹងកាត់បន្ថយភាពអត់ការងារធ្វើពេលបច្ចុប្បន្ន ជាពិសេសនៅរដូវដែលពុំសូវទទួលផលល្អ ។ កំលាំងពលកម្មទាំងនោះ ចំពោះគំរោងសាងសង់នឹងត្រូវបានជួលពីកំលាំងពលកម្មពីអ្នកទទួលផលប្រយោជន៍របស់គំរោង ។

(5) **ជំរុញឱ្យមានឧស្សាហកម្មជនបទ** : កសិ-ឧស្សាហកម្ម និង វិស័យសេវាកសិ-ទំនាក់ទំនង (Argi-related service sectors) នឹងមានសកម្មភាពការងារដោយបន្ថែមតំលៃដល់កសិផល និង ការពង្រីកការរកស៊ីពីទុនចំណាយកសិកម្ម ។ គំរោងមានឥទ្ធិពលទៅលើសេដ្ឋកិច្ចមូលដ្ឋាន រួមមានឧស្សាហកម្ម និងសេវាកម្មដែលជាកត្តាដ៏មានសារៈសំខាន់បំផុត ។

86. **សិក្ខាសាលាវាយតំលៃការចូលរួមយ៉ាងរហ័សនៅជនបទ** (PRA):

សិក្ខាសាលា 10 កន្លែងបានប្រព្រឹត្តឡើងក្នុងអំឡុងរយៈពេល 2 ថ្ងៃ ចាប់ពីថ្ងៃទី 05 និង 06 ខែ ធ្នូ ឆ្នាំ 2001 បានទទួលយោបល់ និង ការចង្អុលបង្ហាញពីអ្នកចូលរួមទទួលផលប្រយោជន៍ បុគ្គលិករដ្ឋបាលក្នុងស្រុក និងអង្គការក្រៅរដ្ឋាភិបាល (NGOs) ដែលបានជាប់ទាក់ទង ។ សិក្ខាសាលាដែលបានប្រព្រឹត្តឡើងសំខាន់លើប្រធានបទជាបន្តបន្ទាប់ និងបញ្ចប់នូវពង្រាងផែនការសិក្សាអ្វីៗ ដែលអាចធ្វើបានដោយអ្នកចូលរួមព្រមទទួលក្នុងពេលសិក្ខាសាលា :

- ផែនការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រព ដូចជា USP SRP និង PDP
- ពត៌មានវិធីដំណើរការនៃសហគមន៍កសិករប្រើប្រាស់ទឹក FWUC
- តួនាទី និង ការងារនៃ FWUC
- សិទ្ធិ និង កាតព្វកិច្ចនៃ (FWUC) និងសមាជិក (FWUC)
- អ្នកចូលរួមដើម្បីអភិវឌ្ឍន៍លើកសិដ្ឋាន
- ជំនួយការសេវាកម្មទីផ្សារនៃ (FWUC)

- សំណើ ISF

- ស្ថាប័នអភិវឌ្ឍន៍ និងកម្មវិធីកសាងសមត្ថភាព

87. **ការសន្និដ្ឋាន និង ការណែនាំ**

- USP គ្របដណ្ដប់ផ្ទៃដីស្រោចស្រព 3.500 ហិចតា មានលទ្ធភាពសេដ្ឋកិច្ច និង ហិរញ្ញវត្ថុគ្រប់គ្រាន់ ។ ភាពសំខាន់នៃគំរោងប៉ះពាល់ទៅលើសេដ្ឋកិច្ចមូលដ្ឋានដោយប្រាក់ចំណូលបន្ថែម និង ការងារកើតឡើង ការបង្កើតស្បៀងគ្រប់គ្រាន់ដោយខ្លួនឯងក្នុងតំបន់ និងលើកតំកើនឧស្សាហកម្មជនបទ គឺបានពិចារណាជាសំខាន់ ។ អ្នកចូលរួមទទួលផលប្រយោជន៍ផ្ទាល់ដែលបានប៉ាន់ស្មានលើសពី 20.000 នាក់ ខណៈដែលអ្នកចូលរួមទទួលផលប្រយោជន៍ប្រយោល ដោយផ្ដល់នូវភាពមាំទាំនៃស្រូវដែលបានប៉ាន់ស្មានលើសចំនួនប្រជាជនទាំងអស់នៃស្រុកត្រាំកក់ 144.000 នាក់ ។

- អាងទឹកកំសី SRP និងអាងទឹក 160 SRP បានចង្អុលបង្ហាញលទ្ធភាពសេដ្ឋកិច្ចខ្ពស់ ខណៈដែលផលប៉ះពាល់ដល់កសិករ អ្នកចូលរួមផលប្រយោជន៍នឹងមានកំរិត ពីព្រោះ SRPs អាចស្រោចស្រពមួយផ្នែកនៃដីកសិកម្មដូចជា 27 ហិចតា សំរាប់អាងទឹកកំសី និង 25 ហិចតា សំរាប់អាងទឹក 160 ដែលបានប្រព្រឹត្តឡើងដោយកសិករ (37 និង 130 គ្រួសារជាអ្នកត្រួតពិនិត្យ និងគ្រប់គ្រង) ។

- គំរោងអភិវឌ្ឍន៍ស្រះទឹកតូចៗ (PDP) បានចង្អុលបង្ហាញពីការលៃលកលទ្ធភាពសេដ្ឋកិច្ច ប៉ុន្តែភាពសំខាន់ទៅលើសេដ្ឋកិច្ចកសិដ្ឋាន ក្នុងពេលនៃការបង្កើនប្រាក់ចំណូលសុទ្ធ គឺតិចជា USP និង SRP ។

- ផែនការធ្វើឱ្យល្អឡើងវិញផ្លូវលំជនបទ (RIP) មានលទ្ធភាពសេដ្ឋកិច្ចខ្ពស់ ។ ផលប៉ះពាល់សេដ្ឋកិច្ចទៅកាន់តំបន់ខាងលើនៃ USP (1.477 ហិចតា ដីកសិកម្ម) ហើយតទ្ធិពលក្រៅតំបន់ (4.004 ហិចតា) គ្របដណ្ដប់គ្រួសារសរុបប្រមាណ 4.400គ្រួសារ ក្នុងឆ្នាំ 2001 ដែលនឹងគិតជាសំខាន់ ។ ផ្លូវថ្នល់ចូលទៅកាន់អាងទឹកទំនប់លោកនៃ USP គឺជាផ្លូវថ្នល់មួយនៃ RIP ស្ថិតក្នុងស្ថានភាពអាក្រក់នៅពេលបច្ចុប្បន្ននេះនឹងត្រូវការក្នុងការស្ដារឡើងវិញសំរាប់កិច្ចប្រតិបត្តិការជាក់ស្ដែងនៃ USP ។ ការអភិវឌ្ឍន៍នៃតំបន់ក្រៅតទ្ធិពលនឹងបានបង្កើនល្បឿនផងដែរដោយ (RIP) ។ អ្នកចូលរួមទទួលផលប្រយោជន៍ផ្ទាល់ដែលបានប៉ាន់ស្មានមានចំនួនលើសពី 20.000 នាក់ ។

- គំរោងខាងលើនឹងមិនបង្កើតផលប៉ះពាល់អ្វីដល់បរិស្ថានឡើយ ។

- ដាក់ការប៉ាន់ស្មានខាងលើទៅក្នុងការពិចារណា តំរូវការជាអាទិភាពនៃកិច្ចប្រតិបត្តិគំរោងបានចាប់ផ្ដើមដែលអាចសំរេចបានយ៉ាងរហ័សក្នុងបទបញ្ជា អនុវត្តន៏ផែនការតំរូការអភិវឌ្ឍន៏ ប្រហាក់ប្រហែលគ្នាក្នុងសក្ដានុពលសកម្មភាពផ្សេងៗនៃតំបន់ក្នុងប្រទេសកម្ពុជា ដូចជាការបង្កើនមូលដ្ឋានស្រោចស្រព ក្នុងការអភិវឌ្ឍន៏ជនបទនៃគំរោងតំបន់ផងដែរ ។ កិច្ចប្រតិបត្តិការនឹងបែងចែកឱ្យចំណូលនៃកសិដ្ឋានកើនឡើង ហើយស្តង់ដារការរស់នៅប្រសើរឡើង និងជាទីបញ្ចប់ គឺកាត់បន្ថយភាពក្រីក្រក្នុងប្រទេសកម្ពុជា ។